សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques
Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# បណ្ដឹងអាជ្ញា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


រៀបរៀងដោយ
និស្សិតឈ្មោះ **កញ្ញា ឌន ដានីត្តា**
**លោក ប៉ែន បញ្ញាឬទ្ធិ**

សាស្ត្រាចារ្យណែនាំ
**លោក ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឌន ដានីត្តា** និងខ្ញុំបាទឈ្មោះ **ម៉ែន បញ្ញាឫទ្ធិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២១ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សជាទីបំផុត ដែលមានឱកាសថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

- លោកឪពុក **ជុំ ចាន់ឌន** និងអ្នកម្តាយ **ជី ចិន្តា**
- លោកឪពុក **ម៉ែន ផល្លីភា** និងអ្នកម្តាយ **លឹម ទូច**

ដែលបានចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌ទាំង៤ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ។ ជាងនេះទៅទៀត លោកទាំងពីរបានធ្វើការប្រៀនប្រដៅដល់កូនឱ្យក្លាយជាមនុស្សល្អ ដែលមានសុជីវធម៌ និងចេះស្រលាញ់ដល់សង្គមជាតិរបស់យើង ព្រមទាំងបន្តការជួយទំនុកបម្រុង និងការលើកទឹកចិត្តឱ្យកូនបានបន្តការសិក្សាមកដល់បច្ចុប្បន្ន ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងណែនាំ ព្រមទាំងធ្វើការចង្អុលបង្ហាញស្ថានភាពសង្គមជាក់ស្តែងទៀតផង ។

**លោកសាស្ត្រាចារ្យ ជួន ប៊ុនធី** ដែលជាសាស្ត្រាចារ្យប្រកបដោយគតិបណ្ឌិត ដែលបានផ្តល់កិត្តិយសណែនាំជួយជ្រោមជ្រែង ផ្តល់គំនិតយោបល់ និងជួយកែសម្រួលរាល់កំហុសឆ្គងក្នុងការសរសេរសារណានេះរហូតទទួលបានជោគជ័យ រួមទាំងឯកសារដែលលោកសាស្ត្រាចារ្យបានផ្តល់អោយគឺជាគ្រឹះក្នុងការចងក្រងសារណាមួយនេះ ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់ អ្នកម្តាយ និងលោកឪពុក ឯកឧត្តមសាកលវិទ្យាធិការ លោកលោកស្រី សាស្ត្រាចារ្យទាំងអស់ ជាពិសេសលោកសាស្ត្រាចារ្យ ជួន ប៊ុនធី ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ សូមឱ្យមានសុខភាពពេញបរិបូរណ៍ ជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន សុភមង្គល និងទទួលជោគជ័យគ្រប់ភារកិច្ចការងារៗ ។

# អារម្ភកថា

ជាបឋម យើងខ្ញុំសូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញនីតិសាស្ត្រ ពិតជាមានសេចក្តីសោមនស្សរីករាយជាពន់ពេក ក្នុងការរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី **បណ្តឹងអាជ្ញា** ដែលត្រូវបានទទួលនូវការគាំទ្រ និងការជួយលើកទឹកចិត្តបង្ហាត់បង្រៀនកែតម្រូវពីសំណាក់ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើង ក្នុងគោលបំណងគឺដើម្បីចងក្រងជាឯកសារមួយសម្រាប់ដល់និស្សិតជំនាន់ក្រោយ ឬក៏សារធារណៈជន ដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះ ដើម្បីបង្កើនចំណេះដឹង ក៏ដូចជាប្រើប្រាស់ចំណេះដឹងដែលទទួលបានដើម្បីជាប្រយោជន៍ និងអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ។ ជាងនេះទៅទៀត ពួកយើងខ្ញុំផ្ទាល់ក៏ចង់ដឹង និងចង់សិក្សាឱ្យបានស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតអំពីខ្លឹមសារ និងអត្ថន័យ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាក់ស្តែងទាក់ទងនឹងប្រធានបទនេះផងដែរ ។

ម្យ៉ាងវិញទៀត នៅក្នុងការស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតផ្នែកខ្លឹមសារ និងកំហុសឆ្គងខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ ដូច្នេះយើងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងក្នុងសារណានេះនឹងទទួលបានការអធ្យាស្រ័យ និងការអភ័យទោសពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន ។

ជាទីបញ្ចប់ខ្ញុំ សូមប្រសិទ្ធិពរជ័យជូនដល់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ទទួលបានសេចក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងប្រាថ្នាគ្រប់ៗគ្នា ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ០១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា**

**ផ្នែកទី១៖ និយមន័យ** ........ ០៤

**១.១ អ្វីជាបណ្តឹងអាជ្ញា?** ........ ០៤

១.១.១ ការពិនិត្យអត្ថិភាពនៃបទល្មើស ........ ០៥

១.១.២ ការពិនិត្យពិរុទ្ធភាពនៃជនល្មើស ........ ០៦

១.១.៣ ការផ្តន្ទាទោសជនល្មើស ........ ០៦

១.១.៣.១ បទឧក្រិដ្ឋ ........ ០៧

១.១.៣.២ បទមជ្ឈិម ........ ០៧

១.១.៣.៣ បទលហុ ........ ០៧

**១.២ ប្រៀបធៀបបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី** ........ ០៧

១.២.១ គោលបំណង ........ ០៨

១.២.២ មូលដ្ឋានផ្នែកច្បាប់ ........ ០៨

១.២.៣ ប្រភេទ ........ ០៨

១.២.៤ ទណ្ឌកម្ម ........ ០៨

១.២.៥ ភាគីនៃបណ្តឹង ........ ០៨

**១.៣ កម្មវត្ថុនៃបណ្តឹងអាជ្ញា** ........ ០៨

១.៣.១ បណ្តឹងអាជ្ញាអនុវត្តទៅលើរូបវន្តបុគ្គល ........ ០៩

១.៣.២ បណ្តឹងអាជ្ញាអនុវត្តទៅលើនីតិបុគ្គល ........ ០៩

**ផ្នែកទី២៖ ភាគីក្នុងបណ្តឹងព្រហ្មទណ្ឌ** ........ ១០

**២.១ អង្គការអយ្យការ** ........ ១១

២.១.១ អំណាចរបស់អង្គការអយ្យការ ........ ១១

២.១.២ សមាសភាពនៃចៅក្រមអង្គអយ្យការ ........ ១២

២.១.២.១ អង្គការអយ្យការអមតុលាការកំពូល ........ ១២

២.១.២.២ អង្គការអយ្យការអមសាលាឧទ្ធរណ៍ ........ ១២

២.១.២.៣ អង្គការអយ្យការអមសាលាដំបូង ........ ១៣

**២.២ ជនល្មើស** ........ ១៤
២.២.១ ជនសង្ស័យ ឬ ជនជាប់សង្ស័យ ........ ១៤
២.២.២ ជនត្រូវចោទ ........ ១៤
២.២.៣ ជនជាប់ចោទ ........ ១៤
២.២.៤ ពិរុទ្ធជន ........ ១៥
២.២.៥ ទណ្ឌិត ........ ១៥
**២.៣ ដើមបណ្តឹងរដ្ឋប្បវេណី** ........ ១៥
**២.៤ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី** ........ ១៥

## ជំពូកទី២
## ដំណើរការនៃបណ្តឹងអាជ្ញាក្នុងនីតិវិធីតុលាការ

**ផ្នែកទី១៖ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញា** ........ ១៧
**១.១ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយតំណាងអយ្យការ** ........ ១៧
**១.២ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ** ........ ១៧
១.២.១ ការដាក់ពាក្យប្តឹងតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ ........ ១៨
១.២.២ ការដាក់ពាក្យប្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរ ........ ១៨
១.២.៣ របៀបនៃការសរសេរបណ្តឹង ........ ១៩
**ផ្នែកទី២៖ ចំណាត់ការលើពាក្យប្តឹងក្នុងរឿងព្រហ្មទណ្ឌ** ........ ១៩
**២.១ ចំណាត់ការលើពាក្យប្តឹងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌** ........ ២០
**២.២ ចំណាត់ការលើបណ្តឹងក្នុងដំណាក់កាលអយ្យការ** ........ ២០
២.២.១ ការតម្កល់រឿងទុកឥតចាត់ការ ........ ២១
២.២.១.១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២១
២.២.១.២ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២១
២.២.១.៣ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ ........ ២២
២.២.២ កាលានុវត្តភាពនៃការចោទប្រកាន់ ........ ២៣
២.២.២.១ ការបើកការស៊ើបសួរ ........ ២៣
២.២.២.២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........ ២៤
២.២.២.៣ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ........ ២៤

# ជំពូកទី៣
# ការរលត់បណ្តឹងអាជ្ញា

**ផ្នែកទី១៖ មូលហេតុទូទៅនៃការរលត់នៃបណ្តឹងអាជ្ញា**............................................២៧
**១.១ មរណភាពនៃជនល្មើស** ............................................................................................... ២៧
**១.២ ការផុតអាជ្ញាយុកាល**.....................................................................................................២៨
១.២.១ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា.................................................................................២៨
១.២.២ អាជ្ញាយុកាលនៃទោស ............................................................................................២៩
**១.៣ ការលើកលែងទោសជាទូទៅ**............................................................................................២៩
១.៣.១ អានុភាព...........................................................................................................២៩
១.៣.២ ការបន្ធូរបន្ថយ និងការលើកលែងទោសនៅពិធីបុណ្យជាតិ .......................................៣០
១.៣.៣ លក្ខខណ្ឌការបន្ធូរបន្ថយទោស និងការលើកលែងទោសទណ្ឌិត.............................៣០
១.៣.៣.១ លក្ខខណ្ឌទូទៅ ...........................................................................................៣០
១.៣.៣.២ លក្ខខណ្ឌដោយឡែក.....................................................................................៣១
**១.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ** ........................................................................................ ៣២
១.៤.១ និរាករណ៍នៃច្បាប់ដោយតុណ្ឌីភាព..........................................................................៣៣
១.៤.២ និរាករណ៍នៃច្បាប់ដោយមានការបង្ហាញខ្លួននៃច្បាប់ថ្មី...........................................៣៣
**១.៥ អាជ្ញាអស់ជំនុំ**..................................................................................................................៣៣
**ផ្នែកទី២៖ មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹងអាជ្ញា** .........................................៣៤
**២.១ ការសម្របសម្រួលដោយរដ្ឋ** ...........................................................................................៣៤
**២.២ ការដកពាក្យប្តឹង**...........................................................................................................៣៤
**២.៣ ការបង់ប្រាក់ពិន័យសរុបដើម្បីសម្របសម្រួលជាមួយរដ្ឋ**...............................................៣៥
**សេចក្តីសន្និដ្ឋាន**....................................................................................................................៣៦
**អនុសាសន៍** ..........................................................................................................................៣៨
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

មនុស្សរស់នៅលើសកលលោកយើងនេះ រមែងតែងតែចង់រស់នៅក្នុងសង្គមមួយដែលមានសុខសន្តិភាពពេញលេញ មានការគោរពសិទ្ធិមនុស្សបរិបូរណ៍ ជាពិសេសគឺជាប្រទេសដែលមានការអភិវឌ្ឍជឿនលឿនលើគ្រប់វិស័យដែលធ្វើឱ្យការរស់នៅរបស់ពួកគាត់ប្រកបដោយភាពសប្បាយរីករាយទាំងផ្លូវកាយ និងផ្លូវចិត្ត ។ គ្រប់គ្នាចង់បានការរស់នៅដែលមានអាហារហូបចុកគ្រប់គ្រាន់ មានសិទ្ធិសេរីភាពពេញលេញ ការគោរពឱ្យតម្លៃគ្នាទៅវិញទៅមក គ្មានអំពើកេងប្រវ័ញ្ច និងត្រូវបានការពារពីរដ្ឋដោយតម្លាភាព គណនេយ្យភាព និងសមធម៌។

ទោះជាយ៉ាងណាក៏ដោយ អកុសលទាំងបីរួមមាន លោភៈ ទោសៈ និងមោហៈ ញ៉ាំងឱ្យមនុស្សប្រព្រឹត្តនូវបទល្មើសផ្សេងៗនៅក្នុងសង្គមដូចជា ការកាប់សម្លាប់ រំលោភ លួច អំពើហិង្សា ការកេងប្រវ័ញ្ចអ្នកដទៃ និងអំពើផ្សេងៗទៀតដែលសង្គមថ្កោលទោស ។ បទល្មើសទាំងនេះប្រៀបដូចជាដំបៅក្នុងការបំផ្លាញទៅដល់តម្រូវការរបស់មនុស្ស ជារនាំងឃាំងនៅសិទ្ធិសេរីភាពរបស់មនុស្ស និងជាអាវុធបំផ្លាញទៅដល់ការអភិវឌ្ឍរបស់ប្រទេសជាតិផងដែរ ។

ដោយមើលឃើញពីបញ្ហាទាំងនេះ សង្គមចាំបាច់ត្រូវរកមធ្យោបាយក្នុងការបង្ការ បង្ក្រាប និងទប់ស្កាត់នូវអំពើទាំងឡាយដែលបានកើតឡើងបង្កនូវផលប៉ះពាល់អវិជ្ជមានដល់សង្គម ។ មធ្យោបាយសំខាន់ៗដែលបណ្តាប្រទេសនៅលើសកលលោកបានបង្កើតឡើងក្នុងគោលបំណងដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ គឺការរៀបចំតាក់តែងនូវលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីគ្រប់គ្រងសង្គមមួយឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។ ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជាបានបង្កើតរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសដំបូងតាំងពីឆ្នាំ ១៩៤៧ មកម៉្លេះ ។ ក្រោយមក ក៏មានការផ្លាស់ប្តូររដ្ឋធម្មនុញ្ញចំនួន៦លើក រហូតដល់ឆ្នាំ ១៩៩៣ ទើបកម្ពុជាបានបង្កើតរដ្ឋធម្មនុញ្ញឡើងវិញនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដែលកំណត់ពីរបបនៃការដឹកនាំ ការបែងចែកអំណាច និងមុខងាររដ្ឋាភិបាល សិទ្ធិសេរីភាពប្រជាពលរដ្ឋ និងការធានានូវឯករាជ្យភាពរបស់តុលាការផងដែរ ។

ដោយមើលឃើញពីកង្វះខាតនៃច្បាប់ទាក់ទងនឹងការរៀបចំនូវរចនាសម្ព័ន្ធច្បាប់ និងប្រព័ន្ធតុលាការកម្ពុជាបានបង្កើតច្បាប់អនុវត្តក្នុងគ្រាបណ្តោះអាសន្ន ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជានាសម័យអន្តរកាលនោះ ឬហៅកាត់ថាច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ។ នៅឆ្នាំ២០០៧ ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ត្រូវបានបង្កើតឡើងដើម្បីកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយម៉ត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យការអនុវត្តនីតិវិធីក្នុងប្រព័ន្ធតុលាការឱ្យទៅមុខបានដោយរលូនក្នុងការធានាដល់ប្រសិទ្ធិភាព ក៏ដូចជាឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ក្នុងសង្គមផងដែរ។ ជាក់ស្តែង បណ្តឹងអាជ្ញាជាចំណុចសំខាន់មួយក្នុងនីតិវិធីព្រហ្មទណ្ឌដែលជាប់ពាក់ព័ន្ធតាំងតែពី ដំណាក់កាល

ដំបូងរហូតដល់ដំណាក់ចុងក្រោយ និងទាមទារឱ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវស្វែងយល់ឱ្យបានច្បាស់ពីគោលការណ៍ និងនីតិវិធីទាំងនេះ ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅទាក់ទងនឹងបណ្តឹងអាជ្ញា យើងត្រូវតែស្វែងយល់ទៅលើចំណុចសំខាន់ៗដូចជា៖

- តើសញ្ញាណទូទៅនៃបណ្តឹងអាជ្ញាមានលក្ខណៈដូចម្តេចខ្លះ ?
- តើភាគីណាខ្លះមានសិទ្ធិចាប់ផ្តើមបណ្តឹងអាជ្ញា ?
- នៅពេលដែលមានបណ្តឹងអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌកើតឡើង តើស្ថាប័នតុលាការមានចំណាត់ការបែបណាទៅលើពាក្យបណ្តឹងដែលបានទទួល ?
- តើមានមូលហេតុអ្វីខ្លះដែលធ្វើឱ្យអយ្យការសម្រេចរលត់បណ្តឹងអាជ្ញា ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវ និងចងក្រងទៅលើប្រធានបទស្តីពី **បណ្តឹងអាជ្ញា** នេះគឺមានគោលបំណងយ៉ាងមោះមុតថានឹងអាចក្លាយជាប្រយោជន៍សម្រាប់ជនគ្រប់រូបដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែម ដើម្បីបង្កើនជាចំណេះដឹង ឬក៏សម្រាប់យកទៅអនុវត្តផ្សេងៗក្នុងនីតិវិធីតុលាការ ។ ជាពិសេសពួកខ្ញុំពឹងថា ឯកសារនេះនឹងជាមូលដ្ឋានគ្រឹះមួយសម្រាប់បងប្អូនដែលស្រលាញ់ និងចង់សិក្សាបន្ថែមទៅលើវិស័យច្បាប់ ក៏ដូចជាអាចជួយជម្រុញឱ្យប្រជាជនចូលចិត្តទៅលើការអាន និងសិក្សាស្រាវជ្រាវដែលជាចំណែកមួយជួយដល់សង្គមក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធិភាព ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដែនកំណត់នៃការស្រាវជ្រាវអំពីប្រធានបទនៃសារណានេះគឺ យើងខ្ញុំនឹងបង្ហាញពីសញ្ញាណទូទៅនៃបណ្តឹងអាជ្ញា ចំណាត់ការទៅលើបណ្តឹងអាជ្ញាតាំងតែពីការដាក់ពាក្យប្តឹងរហូតដល់បញ្ជូនទៅដល់ដំណាក់កាលធ្វើការចោទប្រកាន់ ព្រមទាំងមូលហេតុនៃការរលត់នៃបណ្តឹងអាជ្ញា ។

សម្រាប់ឯកសារស្រាវជ្រាវជាគោល គឺពួកខ្ញុំផ្អែកសំខាន់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ និងឯកសារសំខាន់ៗផ្សេងទៀតដូចជា សៀវភៅដែលរៀបរៀងដោយសាស្ត្រាចារ្យ អត្ថបទច្បាប់ផ្សេងៗ និងការសាកសួរពីសាស្ត្រាចារ្យជាដើម។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះគឺបានផ្តល់នូវគុណប្រយោជន៍ និងគុណតម្លៃជាច្រើនទាំងចំណេះដឹងទាក់ទងនឹងប្រធានបទ របៀបនៃការធ្វើការស្រាវជ្រាវ ក៏ដូចជាការស្វែងរកនូវឯកសារផ្សេងៗ ។ ជាងនេះទៅទៀត ការស្រាវជ្រាវនេះក៏បានជួយឱ្យពួកខ្ញុំបានយល់កាន់តែច្បាស់ និងស៊ីជម្រៅបន្ថែមពីអ្វីដែលបានរៀននៅសាលាទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌមួយនេះ ។ ថ្វីត្បិតតែ ការស្រាវជ្រាវនេះគឺផ្តោតសំខាន់តែបណ្តឹងអាជ្ញា តែវាមានទំនាក់ទំនងយ៉ាងស៊ីជម្រៅទៅក្នុងមេរៀនទាំងមូលនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជាពិសេស សារធារណជនគ្រប់រូបអាចសិក្សាស្វែងយល់កាន់តែស៊ីជម្រៅពីគោលការណ៍ទូទៅនៃបណ្តឹងអាជ្ញា ព្រមទាំងនីតិវិធីផ្សេងៗដែលអនុវត្តក្នុងរឿងក្តីព្រហ្មទណ្ឌបានផងដែរ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ខ្លឹមសារ ឯកសារ និងព័ត៌មានទាំងឡាយដែលយកមកចងក្រងក្នុងសារណាមួយនេះ គឺបានឆ្លងកាត់ការស្រាវជ្រាវដូចខាងក្រោម៖

- ធ្វើការស្រាវជ្រាវសៀវភៅច្បាប់ដែលខ្លួនមានតាមបណ្ណាល័យ និងតាមប្រព័ន្ធអ៊ីនធឺណិត ។
- ប្រើប្រាស់សៀវភៅច្បាប់ដូចជា ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងសៀវភៅមេរៀនផ្សេងៗដែលសាស្ត្រាចារ្យច្បាប់បានចងក្រង ។
- ការស្រាវជ្រាវពីការចែករំលែករបស់សាស្ត្រាចារ្យច្បាប់ និងអ្នកវិជ្ជាជីវៈច្បាប់ តាមកម្មវិធីវិទ្យុ កម្មវិធីបកស្រាយច្បាប់តាមកញ្ចក់ទូរទស្សន៍ សិក្ខាសាលា និងសារព័ត៌មានផ្សេងៗ ។
- ការសាកសួរដោយផ្ទាល់ពីសាស្ត្រាចារ្យផ្នែកច្បាប់ និងសិស្សច្បង ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានចែកចេញជា ០៣ (បី) ជំពូក ៖

ជំពូកទី១៖ សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា ។

ជំពូកទី២៖ ដំណើរការនៃបណ្តឹងអាជ្ញាក្នុងនីតិវិធីតុលាការ ។

ជំពូកទី៣៖ ការរលត់បណ្តឹងអាជ្ញា ។

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌ គឺជាប់ទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌ ។ បទល្មើសព្រហ្មទណ្ឌគឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ដោយផ្ទាល់ ឬ ដោយប្រយោលក្តី ដែលអំពើទាំងនោះបណ្តាលឱ្យប៉ះពាល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ឬ សន្តិសុខសង្គម ហើយដែលត្រូវបានកំណត់ទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ ។ កាលណាមានបុគ្គលដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលនាំឱ្យគ្រោះថ្នាក់ដល់សង្គម ឬ ប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ ជននោះអាចនឹងមានទណ្ឌកម្មពិន័យជាប្រាក់ និងដាក់ពន្ធនាគារក្នុងការកំណត់ណាមួយ ឬ ដាក់ពន្ធនាគារមួយជីវិត។

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើង បណ្តឹងដែលអាចកើតមានឡើង គឺមានពីរប្រភេទ ដែលត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺបណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី ។ តែទោះជាយ៉ាងណាក៏ដោយ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងគ្នា[1] ។

នៅក្នុងស្ថាប័នយុត្តាធិការ មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[2] ។ ជាទូទៅបណ្តឹងអាជ្ញា ជានិច្ចកាលត្រូវតែផ្តួចផ្តើមឡើងដោយព្រះរាជអាជ្ញា ។ ប៉ុន្តែ ជនរងគ្រោះណាម្នាក់នៃបទល្មើសណាមួយក៏អាចដាក់បណ្តឹងអាជ្ញាអោយមានចលនាតាមរយៈការដាក់ពាក្យបណ្តឹងទៅមន្ត្រីនគរបាលយុត្តធម៌ ឬ ទៅអយ្យការអមសាលាដំបូងរាជធានី-ខេត្តដែលមានភារកិច្ចបើកការស៊ើបអង្កេតបឋម[3] ។ អាជ្ញាធរសាធារណៈ និងមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន នៅពេលបានដឹងអំពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់ជាមួយផង (លើកលែងតែមន្ត្រីទាំងនោះមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ ឬ ច្បាប់បញ្ញត្តិថាជាករណីលើកលែង)[4] ។

## ផ្នែកទី១៖ និយមន័យ

### ១.១ អ្វីជាបណ្តឹងអាជ្ញា?

បណ្តឹងអាជ្ញាគឺជាបណ្តឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់ដែលបានកំណត់[5] ។

នេះមានន័យថា បណ្តឹងអាជ្ញាត្រូវបានគេមើលឃើញថាជាបណ្តឹងប្រឆាំងនឹងជនល្មើស ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដោយឆ្លងកាត់នូវការស៊ើបអង្កេតដោយស្ថាប័នអយ្យការ និងបង្ហាញនូវពិរុទ្ធភាពនៃជនល្មើសនោះថា តើមានបទល្មើសណាមួយកើតឡើងដែរឬទេ និងធ្វើការទាមទារអោយតុលាការអនុវត្តនីតិវិធីដើម្បីផ្តន្ទាទោសជននោះទៅតាមច្បាប់បានកំណត់ ។

---

[1] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[2] មាត្រា ១៣១ ថ្មី (មាត្រា ១១២ ចាស់) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

[3] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[4] មាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[5] មាត្រា ២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

### ១.១.១ ការពិនិត្យអត្ថិភាពនៃបទល្មើស

បណ្តឹងអាជ្ញាគឺជាបណ្តឹងដែលពិនិត្យជាមុនសិនថា ពិតជាមានបទល្មើសកើតឡើងឬអត់ ។ ប្រសិនបើមានបទល្មើសកើតឡើង ទើបព្រះរាជអាជ្ញាចាប់ផ្តើមធ្វើការចោទប្រកាន់ទៅលើជនល្មើសនោះ ។

មុននឹងឈានទៅរកការពិនិត្យអត្ថិភាពថាមានបទល្មើស យើងគួរគប្បីយល់ឱ្យបានច្បាស់ពីនិយមន័យនៃបទល្មើស និងធាតុផ្សំដែលអាចចាត់ទុកថា បង្កើតបានជាបទល្មើសជាមុនសិន ។ ចំពោះពាក្យថាបទល្មើសបានន័យថា គឺជាការរំលោភបំពានទៅលើអ្វីមួយដែលច្បាប់បានកំណត់ទុកជាវិធាន ។ បើតាមភាសាច្បាប់ បទល្មើស គឺជាសកម្មភាពមួយដែលមានចែងក្នុងច្បាប់ និងដាក់ទណ្ឌកម្មដោយច្បាប់កំណត់ ។ បើយោងតាមក្រមព្រហ្មទណ្ឌកម្ពុជាវិញ បានចែងថាបទល្មើសគឺជាអំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម[6] ។

អំពើមួយអាចក្លាយជាបទល្មើសបាន គឺទាមទារឱ្យមានធាតុផ្សំ៣ គឺធាតុនីត្យានុកូល ឬ គោលការណ៍នីត្យានុកូលភាព ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ និងធាតុអត្តនោម័ត។

ធាតុនីត្យានុកូល ឬ គោលការណ៍នីត្យានុកូលភាពបានកំណត់ថាមានតែអំពើ ដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចប្រកាសបាន[7] ។ នេះមានន័យថាសកម្មភាព ឬ អំពើទាំងឡាយណាដែលជាបទល្មើសអាចត្រូវបានផ្តន្ទាទោស គឺលុះត្រាតែមានចែងនៅក្នុងច្បាប់ ។

ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈជាផ្នែកខាងក្រៅនៃបទល្មើសដែលជាអ្វីដែលបទល្មើសបានចេញឱ្យឃើញរួមមាន[8] ៖

- អំពើគ្រោះថ្នាក់ដល់សង្គម
- បច្ច័យគ្រោះថ្នាក់នៃសង្គម (ការអន្តរាយ)
- ទំនាក់ទំនងហេតុផលរវាងអំពើ និងបច្ច័យ
- បណ្តាសញ្ញាផ្សេងៗដែលស្តែងចេញអំពីការប្រព្រឹត្តអំពើ (បទល្មើស) និងផ្សារភ្ជាប់ជាមួយអំពើនោះនូវឧបករណ៍មធ្យោបាយ វិធីសាស្ត្រ ឧបាយកល ពេលវេលា ទីកន្លែង និងទិដ្ឋភាពនានានៃបទល្មើស ។

ធាតុអត្តនោម័តបានន័យថាពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែ ក្នុងករណី ដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ[9] ។ ជាធម្មតាប្រសិនបើអយ្យការមើលឃើញថា មានអំពើបង្កភាពវឹកវរកើតឡើងដល់សង្គម និងសណ្តាប់ធ្នាប់សាធារណៈ ឬ មានបទល្មើសព្រហ្មទណ្ឌកើតឡើងនោះ អយ្យការមាន

[6] មាត្រា ២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[7] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[8] មេរៀន នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយៈ ឯកឧត្តម ហ៊ី សោភា ។

[9] មាត្រា ៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

តួនាទីមួយ គឺក្នុងការដាក់បណ្តឹងអាជ្ញាតាងនាមជាអ្នកការពារផលប្រយោជន៍សាធារណៈ ។ ចំណុចដំបូងដែលអយ្យការត្រួតពិនិត្យ គឺមានបទល្មើសកើតឡើងឬអត់។ គេហៅថាជាការពិនិត្យអត្ថិភាព នៃបទល្មើស ។ បើតាមធាតុផ្សំនៃបទល្មើសដូចបានរៀបរាប់ខាងលើនេះ គឺអំពើមួយរបស់ចារីអាចជាបទល្មើស លុះណាតែជាអំពើដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌថាវាជាបទល្មើស ។ មានច្បាប់ចែងថា ជាបទល្មើសទើបមានទោស ជាអំពើដែលចារីមានចេតនាប្រព្រឹត្តនាំអោយបង្កឱ្យគ្មានសណ្តាប់ធ្នាប់ក្នុងសង្គម ឬ គ្មានចេតនា ប្រព្រឹត្តដែលវាកើតពីការធ្វេសប្រហែសដែលបង្កជាព្យសនកម្មដល់សណ្តាប់ធ្នាប់សង្គម និងជាអំពើសកម្ម ឬ អកម្មក្តីដែលចារីបានប្រព្រឹត្តអំពើនោះពិតមែន ឬប៉ុងប៉ងប្រព្រឹត្ត ។

ធាតុសត្យានុម័ត និងធាតុអត្តនោម័តមានទំនាក់ទំនងជិតស្និតនឹងគ្នា ដោយសារថាធាតុសត្យានុម័តស្តែងចេញមកក្រៅ ឯធាតុអត្តនោម័តវិវឌ្ឍន៍នៅក្នុងចិត្តរបស់ជនល្មើស ។ ធាតុសត្យានុម័ត និងធាតុអត្តនោម័តមិនអាចកាត់ផ្តាច់ចេញពីគ្នាបាននោះទេ ។ ធាតុទាំងពីរនេះសម្តែងចេញជាអំពើសកម្ម និងអំពើអកម្ម ។

### ១.១.២ ការពិនិត្យពិរុទ្ធភាពនៃជនល្មើស

ពិរុទ្ធភាពគឺសំដៅទៅលើភាពមានទោសរបស់ជនល្មើស នៅពេលដែលជននោះបានប្រព្រឹត្តអំពើណាដែលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃ ឬសណ្តាប់ធ្នាប់សន្តិសុខសង្គម ដែលអំពើនោះមានចែងនៅក្នុងច្បាប់ថាមានទោស ។ ការពិនិត្យពិរុទ្ធភាពនៃជនល្មើសគឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ដែលមិនពាក់ព័ន្ធនឹងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិឡើយ[10] ។ តុលាការអាចចេញសាលក្រម ឬ សាលដីការដើម្បីកំណត់ពីទោសរបស់ជនល្មើសនោះ បន្ទាប់ពីបានជំនុំជម្រះរួចរាល់ ។ ជាទូទៅ ការពិនិត្យពិរុទ្ធភាពនៃជនល្មើស មានតែទៅលើបណ្តឹងអាជ្ញាមួយគត់ ដែលមានន័យថាបណ្តឹងរដ្ឋប្បវេណី គឺមិនមានការពិនិត្យពីពិរុទ្ធភាពឡើយ ។

### ១.១.៣ ការផ្តន្ទាទោសជនល្មើស

មានតែបណ្តឹងអាជ្ញាទេដែលធ្វើការផ្តន្ទាទោសជនល្មើសទៅតាមទំហំនៃសកម្មភាព ដែលជននោះបានប្រព្រឹត្ត និងមានកំណត់យ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា ។ ជាក់ស្តែង នៅក្នុងន័យច្បាប់ព្រហ្មទណ្ឌ ការផ្តន្ទាទោសជនល្មើស រួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[11] ។ ក្នុងបណ្តឹងរដ្ឋប្បវេណី គឺគ្រាន់តែធ្វើការជួសជុលព្យសនកម្មតាមរយៈការជួសជុលការខូចខាត និងការផ្តល់សំណងជម្ងឺចិត្តប៉ុណ្ណោះ ។ ចំណែកឯ នៅក្នុងបណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌវិញ អាចមានការផ្តន្ទាទោសទៅតាមប្រភេទបទល្មើសដែលជនល្មើសបានប្រព្រឹត្ត ។ បទល្មើសត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទៅតាមទម្ងន់នៃបទល្មើស[12] ។ ការបែងចែកបទល្មើសជាបីប្រភេទតាមលក្ខណៈធ្ងន់ធ្ងរនៃបទល្មើសពិតជាមានសារៈសំខាន់ណាស់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ពីព្រោះថាការបែងចែកនេះនាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្តិ ដែលច្បាប់រមែងភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើស[13] ។

---

[10] យោងតាមសេចក្តីថ្លែងការណ៍របស់ ឯកឧត្តម ជិន ម៉ាលីស ដែលផ្សាយដោយសារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២០ ។

[11] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[12] មាត្រា២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[13] មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ទំព័រទី៤ ចងក្រងដោយ ឯកឧត្តម សឿង មុន្នីរ័ត្ន បកស្រាយដោយ ឯកឧត្តម ហ៊ី សោភា ឯកឧត្តមប៊ុន ហ៊ិន ឯកឧត្តម កើត រិទ្ធ ឯកឧត្តម ផូវ សំភី និងលោកជំទាវ ចាំង ស៊ីណាត ។

**១.១.៣.១ បទឧក្រិដ្ឋ**

បទឧក្រិដ្ឋជាបទល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលអតិបរមានៃទោសពន្ធនាគារលើសពី៥ឆ្នាំ រហូតដល់ ៣០ ឆ្នាំ និងបើជាបទល្មើសឧក្រិដ្ឋដែលមានស្ថានទម្ងន់ទោសនៃការប្រព្រឹត្តនាំអោយការផ្តន្ទាទោសក្នុងបទឧក្រិដ្ឋមានអតិបរមារហូតដល់ជាប់ពន្ធនាគារអស់មួយជីវិត ។ បទឧក្រិដ្ឋនេះទៀតសោតក៏អាចមានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[14] ។

**១.១.៣.២ បទមជ្ឈិម**

បទមជ្ឈិមជាបទល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី៦ថ្ងៃ និងក្រោម ឬ ស្មើ៥ឆ្នាំ ។ បទមជ្ឈិមក៏អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ដែរ[15] ។

**១.១.៣.៣ បទលហុ**

បទលហុជាបទល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលអតិបរមានៃទោសពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើនឹង៦ថ្ងៃ ។ ទោសពន្ធនាគារក៏អាចត្រឹមតែពិន័យជាប្រាក់ផងដែរ[16] ។

សរុបមកវិញ តាមរយៈការរៀបរាប់អំពីអតិបរមានៃការផ្តន្ទាទោសទៅតាមបទល្មើសព្រហ្មទណ្ឌខាងលើយើងឃើញថា នៅក្នុងបណ្តឹងអាជ្ញាគឺជនល្មើសនឹងត្រូវបានទទួលការផ្តន្ទាទោសទៅតាមប្រភេទនៃបទល្មើសដែលខ្លួនបានប្រព្រឹត្ត ដែលអតិបរមានៃទោសពន្ធនាគារ និងពិន័យជាប្រាក់មានភាពខុសៗគ្នា ទៅតាមប្រភេទបទល្មើសនៃបណ្តឹងអាជ្ញា ។

## ១.២ ប្រៀបធៀបបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីសុទ្ធតែកើតចេញពីអង្គហេតុតែមួយដូចគ្នា ។ ប៉ុន្តែ អំពើខ្លះបណ្តាលឱ្យកើតតែបណ្តឹងអាជ្ញាប៉ុណ្ណោះ មិននាំឱ្យកើតមានបណ្តឹងរដ្ឋប្បវេណីទេ ផ្ទុយមកវិញ អំពើខ្លះក៏នាំឱ្យកើតតែបណ្តឹងរដ្ឋប្បវេណីដែរ ។ កំហុសតែមួយគឺមូលដ្ឋាននៃបណ្តឹងអាជ្ញាផង និងបណ្តឹងរដ្ឋប្បវេណីផង ។ ជាងនេះទៅទៀត បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងក្នុងពេលជាមួយគ្នានៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ ។ ប៉ុន្តែ បណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី[17] ។

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីជាបណ្តឹងពីរផ្សេងគ្នា ដែលយើងអាចធ្វើការកំណត់ពីភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ដោយមើលទៅលើគោលបំណង មូលដ្ឋានផ្នែកច្បាប់ ប្រភេទ ទណ្ឌកម្ម និងភាគីនៃបណ្តឹង[18] ។

[14] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[15] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[16] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[17] មាត្រា ២២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[18] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ **រុន ពុណ្ណារិទ្ធិ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ ២០១៣-២០១៤ ទំព័រទី២ ដល់ទំព័រទី៣ ។

### ១.២.១ គោលបំណង

បណ្តឹងអាជ្ញាមានគោលបំណងការពារសណ្តាប់ធ្នាប់សាធារណៈ ជួសជុលការខូចខាតសណ្តាប់ធ្នាប់សង្គម និងផ្តន្ទាទោសរាល់ការរំលោភច្បាប់ ។ ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញមានបំណងត្រឹមតែជួសជុលព្យសនកម្មផ្ទាល់ខ្លួនដែលកើតឡើងចំពោះជនរងគ្រោះប៉ុណ្ណោះ ។

### ១.២.២ មូលដ្ឋានផ្អែកច្បាប់

បណ្តឹងអាជ្ញាតែងមានមូលដ្ឋានផ្អែកច្បាប់ណាមួយជាកំណត់ ស្របតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស ។ ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញមានមូលដ្ឋានផ្អែកលើការទទួលខុសត្រូវក្រៅកិច្ចសន្យា ឬ អំពើអនីត្យានុកូល ។

### ១.២.៣ ប្រភេទ

បណ្តឹងអាជ្ញាមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ បានសេចក្តីថាពុំអនុញ្ញាតឱ្យមានការលះបង់ ឬបញ្ឈប់តាមទំនើងចិត្តឡើយ លើកលែងតែករណី ដែលច្បាប់បានកំណត់ទុកប៉ុណ្ណោះ ។ ផ្ទុយទៅវិញ បណ្តឹងរដ្ឋប្បវេណីស្ថិតនៅក្នុងបេតិកភណ្ឌឯកជនរបស់ជនរងគ្រោះ ដែលអាចលះបង់ ឬ ក៏សម្រុះសម្រួលតាមចិត្តរបស់ជនរងគ្រោះ ។

### ១.២.៤ ទណ្ឌកម្ម

ទណ្ឌកម្មដែលទាញចេញពីបណ្តឹងទាំងពីរ គឺមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ដោយបណ្តឹងអាជ្ញាអាចនាំទៅដល់ការពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ ដោយផ្អែកជាពិសេសទៅលើភាពធ្ងន់ធ្ងរនៃកំហុស ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញអាចនឹងឈានទៅដល់ការបង់សំណងជម្ងឺចិត្ត ដោយពុំគិតពីភាពធ្ងន់ធ្ងរនៃកំហុសឆ្គងទេ តែគិតទៅតាមព្យសនកម្មដែលកើតឡើងទៅវិញ ។

### ១.២.៥ ភាគីនៃបណ្តឹង

នៅក្នុងភាគីនៃបណ្តឹងអាជ្ញា ភាគីនៃបណ្តឹងគឺអយ្យការជាគូក្តីដើម និងជនជាប់ចោទ ឬជនត្រូវចោទជាភាគីម្ខាងទៀត ។ នៅក្នុងបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ចំណែកឯភាគីម្ខាងទៀតជាជនជាប់ចោទ ឬ សន្តតិជនរបស់ជនជាប់ចោទ ឬ ក៏ជនដែលទទួលខុសត្រូវរដ្ឋប្បវេណី ។

## ១.៣ កម្មវត្ថុនៃបណ្តឹងអាជ្ញា

ជាធម្មតានៅក្នុងសង្គមមួយ បើទោះបីជាមានសុខសន្តិភាពពេញលេញ និងសន្តិសុខសង្គមល្អយ៉ាងណាក៏ដោយ ក៏ប៉ុន្តែ សកម្មភាពអវិជ្ជមានមួយចំនួនដែលអាចចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ នៅតែអាចកើតមានដោយបុគ្គល ឬ ក្រុមបុគ្គល ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គម ។

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ជំនឿ និន្នាការនយោបាយ ដើមកំណើតជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[19] ។ នៅពេលណាដែល រូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តីដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នោះពួកគេគឺត្រូវតែទទួលទណ្ឌកម្មទៅតាមច្បាប់កំណត់ ដោយគ្មានការប្រកាន់បក្សពួក ឬ មានការរើសអើងឡើយ ដែលនេះបង្ហាញពីតម្លាភាពក្នុងការអនុវត្តច្បាប់ ។

[19] មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

### ១.៣.២ បណ្តឹងអាជ្ញាអនុវត្តទៅលើនីតិបុគ្គល

នីតិបុគ្គលជាក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរ តែដទៃពីសមាជិកនៃខ្លួន[20] ។ បើក្រឡេកទៅមើលក្នុងសន្ធានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺបានកំណត់ថានីតិបុគ្គលជាក្រុមមនុស្ស ឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច ។ ឧទាហរណ៍៖ សមាគម ក្រុមហ៊ុន ។ល។[21] នីតិបុគ្គលត្រូវបានបែងចែកជា២ គឺនីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ ។ នីតិបុគ្គលឯកជនគឺជាក្រុមមនុស្សដែលរួមគ្នាបង្កើតឡើងដើម្បីផលប្រយោជន៍ឯកជន ចំណែកឯនីតិបុគ្គលសាធារណៈ គឺកើតឡើងពីគំនិតផ្តួចផ្តើមនៃអាជ្ញាធររដ្ឋ ឬអាជ្ញាធរសាធារណៈ[22] ។

ក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ[23] ។ និយាយម៉្យាងទៀត ការទទួលខុសត្រូវរបស់នីតិបុគ្គលពុំមានលក្ខណៈទូទៅឡើយ គឺការទទួលខុសត្រូវនេះអាចកើតមានឡើង លុះត្រាតែ មានអត្ថបទច្បាប់ពិសេសប្រកាសអំពីការទទួលខុសត្រូវនេះចំពោះការចោទប្រកាន់ជាក់លាក់មួយប៉ុណ្ណោះ ។ ក្នុងការកំណត់ប្រភេទគតិយុត្តនៃបទល្មើសដែលត្រូវបានប្រព្រឹត្តដោយនីតិបុគ្គលថា ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ នោះត្រូវសិក្សាពីទោសដែលត្រូវទទួលរងដោយរូបវន្តបុគ្គលជាមុនសិន ។ ទន្ទឹមនឹងនេះដែរ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩ ក៏បញ្ញត្តិពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អង្គភាពដែលបំពានមាត្រាមួយចំនួននៃច្បាប់ ហើយនឹងត្រូវពិន័យជាប្រាក់ពី៥លានរៀល ដល់១៥០លានរៀល រួមទាំងការបិទគ្រឹះស្ថានផងដែរ[24] ។ ទោះបីជា នីតិបុគ្គលត្រូវទទួលខុសត្រូវដូចរូបវន្តបុគ្គលក៏ដោយ ចំពោះនីតិបុគ្គល គេពុំអាចប្រកាសទោសឱ្យជាប់ពន្ធនាគារបានឡើយ គឺមានតែទោសពិន័យជាប្រាក់ និងទោសបន្ថែមទៀតប៉ុណ្ណោះ ដែលអាចអនុវត្តបាន ។

## ផ្នែកទី២៖ ភាគីក្នុងបណ្តឹងព្រហ្មទណ្ឌ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌមានភាគីយ៉ាងហោចណាស់ពីរ គឺម្ចាស់បណ្តឹងអាជ្ញា និងជនល្មើស ។ ប៉ុន្តែក្នុងករណីខ្លះទៀត អាចមានបុគ្គលច្រើនជាងនេះទៅទៀតដែលចូលរួមជាភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌមានដូចជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

នៅក្នុងបណ្តឹងអាជ្ញា ភាគីនៃបណ្តឹងគឺអយ្យការជាគូក្តីដើម និងជនជាប់ចោទ ឬ ជនត្រូវជាប់ចោទជាភាគីម្ខាងទៀត ។ ចំណែកឯនៅក្នុងបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ចំណែកឯ

[20] សន្ធានុក្រមនៃច្បាប់ភូមិបាល ឆ្នាំ២០០១ ។

[21] សន្ធានុក្រមនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[22] សៀវភៅនីតិរដ្ឋប្បវេណី រៀងរៀងដោយសាស្ត្រាចារ្យ ហាប់ ផល្លី ឆ្នាំ ២០០១ ទំព័រ ៣៤ និង ៣៥ ។

[23] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[24] មាត្រា ៣៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩ ។

ភាគីម្ខាងទៀតជាជនជាប់ចោទ ឬ សន្តតិជនរបស់ជនជាប់ចោទ ឬ ក៏ជនដែលទទួលខុសត្រូវខាងរដ្ឋប្បវេណី ដូចជាឪពុកម្តាយ ឬ អាណាព្យាបាលរបស់ជនល្មើសជាអនីតិជនជាដើម[25] ។

## ២.១ អង្គការអយ្យការ

### ២.១.១ អំណាចរបស់អង្គការអយ្យការ

អង្គការអយ្យការជាម្ចាស់បណ្តឹងអាជ្ញាមាននៅអមគ្រប់សាលាជម្រះក្តី ដែលបំពេញតួនាទីការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ ។ អង្គការអយ្យការ ឬ ស្ថាប័នអយ្យការ ដែលអមតុលាការខេត្ត-រាជធានីមានតួនាទីក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាកោះហៅបញ្ជូនរឿងឱ្យទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលបង្ហាញខ្លួនភ្លាម ដីកាសន្និដ្ឋានស្ថាពរ និងការធ្វើសេចក្តីថ្លែងការប្តឹងសុំដោយផ្ទាល់មាត់នៅដំណាក់កាលជំនុំជម្រះ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។ មានន័យថាស្ថាប័នអយ្យការមានតួនាទីអនុវត្តសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រម ដូចជាការអនុវត្តសាលក្រមតុលាការ ការអនុវត្តការចាប់ខ្លួនតាមដីកាចាប់ខ្លួន និងការផ្សព្វផ្សាយដីកាឱ្យចាប់ខ្លួនជាដើម ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងជាសាធារណៈដោយផ្ទាល់ជាជំនួយ ។ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនការរឿងក្តីព្រហ្មទណ្ឌ[26] ។ ក្នុងករណីដែលសវនការទៅលើរឿងក្តីព្រហ្មទណ្ឌមិនមានវត្តមានតំណាងអយ្យការ គឺនាំឱ្យមានមោឃភាពនីតិវិធី ។

មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះត្រូវបែងចែកដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្តីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នេះទេសាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ[27] ។

ស្ថាប័នអយ្យការជាស្ថាប័នមានឋានានុក្រម គឺចៅក្រមខាងអយ្យការត្រូវធ្វើតាមបញ្ជារបស់ថ្នាក់លើរបស់ខ្លួន ដែលបញ្ជាឱ្យធ្វើការចោទប្រកាន់ ទោះខ្លួនយល់ឃើញផ្សេងពីនេះក៏ដោយ ។ ជាពិសេសទៅទៀត រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏ជាថ្នាក់លើរបស់ស្ថាប័នអយ្យការដែរ ហេតុនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្រើអធិបញ្ជារបស់ខ្លួនទៅលើសមាជិកស្ថាប័នអយ្យការណាមួយ[28] ។ ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា គឺប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[29] ។ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅ

[25] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៣ ។

[26] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[27] មាត្រា ៧៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គតុលាការ ឆ្នាំ២០១៤ ។

[28] មាត្រា ២៩ និង ៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[29] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

តាមសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយ ដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចាររបស់ខ្លួន ដែលបានបញ្ចេញនៅពេលសវនការសោះឡើយ[30] ។

### ២.១.២ សមាសភាពនៃចៅក្រមអយ្យការ

សមាសភាពរបស់ចៅក្រមតំណាងអយ្យការមានដូចតទៅ[31]៖

- នៅអមតុលាការកំពូលៈ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។
- នៅអមសាលាឧទ្ធរណ៍មាន៖ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។
- នៅអមសាលាដំបូងរាជធានីខេត្ត និងតុលាការយោធាមាន៖ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

#### ២.១.២.១ អង្គការអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃអង្គការអយ្យការអមតុលាការកំពូល[32] ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទីក្នុងការចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ[33] ។

#### ២.១.២.២ អង្គការអយ្យការអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជាតំណាងនៃអង្គការអយ្យការអមសាលាឧទ្ធរណ៍[34] ។

អគ្គព្រះរាជអាជ្ញាឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចនៅអង្គភាពអយ្យការទាំងឡាយដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរកើតឡើង អគ្គព្រះរាជអាជ្ញាត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តធម៌[35] ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងត្រួតពិនិត្យនគរបាលយុត្តិធម៌ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលទាំងនេះ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬ ភ្នាក់ងារនគរបាលគ្រប់គ្រង ឬ ដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌ ។ បន្ថែមពីនេះទៀត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចូលរួមស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន

[30] មាត្រា ៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[31] មាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[32] មាត្រា ៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[33] មាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[34] មាត្រា ៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[35] មាត្រា ៣៤ មាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

ជាពិសេសគឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន ។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ គ្រប់រូបត្រូវគោរពតាមអធិបញ្ញារបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន[36] ។

### ២.១.២.៣ អង្គការអយ្យការអមសាលាដំបូង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង គឺជាតំណាងអង្គការអយ្យការអមតុលាការនេះ[37] ។

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ ។ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌អនុវត្តអំណាចទាំងអស់ដែលព្រះរាជអាជ្ញាបានផ្តល់ឱ្យ ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ ។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[38] ។

សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញានៃទីលំនៅឋានរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស និងព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស ។

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ[39] ។

នៅពេលមានពាក្យប្តឹងបរិហារដែលបានប្តឹងចូលមកស្ថាប័នអយ្យការដោយផ្ទាល់ ឬ ពាក្យបណ្តឹង ដែលទទួលបានដោយមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីចំណាត់ការលើបណ្តឹង ដែលនាំឱ្យមានការចោទប្រកាន់ ឬ តម្កល់ទុកឥតបានការនូវបទល្មើសព្រហ្មទណ្ឌ ។ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម មុននឹងធ្វើការចោទប្រកាន់ ឬ តម្កល់ទុកឥតចាត់ការ[40] ។

---

[36] មាត្រា ៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[37] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[38] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[39] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[40] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

## ២.២ ជនល្មើស

បើយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មានពាក្យបច្ចេកទេសមួយចំនួនដែលបានប្រើពាក្យខុសៗគ្នា អាស្រ័យទៅតាមដំណាក់កាលនីមួយៗនៃដំណើរការរឿងក្តីព្រហ្មទណ្ឌដូចជា ជនសង្ស័យ ឬ ជនជាប់សង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និងទណ្ឌិតជាដើម ។

ជនល្មើសគឺអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលប្រព្រឹត្តនូវអំពើល្មើសច្បាប់ណាមួយ ដែលខ្លួនត្រូវទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួនតាមច្បាប់កំណត់ ។

ពាក្យបទល្មើសត្រូវបានប្រើប្រាស់ក្នុងន័យ២យ៉ាង គឺន័យតាមប្រជាទូទៅ និងតាមក្រមនីតិវិធី[41] ។ តាមន័យប្រជាទូទៅ ជនល្មើសត្រូវបានប្រជាពលរដ្ឋប្រើសំដៅដល់ជនទាំងឡាយណាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចំណែកឯ តាមក្រមនីតិវិធីព្រហ្មទណ្ឌពាក្យថា ជនល្មើសត្រូវបានប្រើជំនួសពាក្យថា ជនសង្ស័យ ឬ ជនជាប់សង្ស័យនៅក្នុងករណីបទល្មើសជាក់ស្តែង ក៏ប៉ុន្តែ ពាក្យថាជនសង្ស័យ ឬ ជនជាប់សង្ស័យ ក៏គេអាចយកទៅប្រើបានដូចគ្នាផងដែរ ។

### ២.២.១ ជនសង្ស័យ ឬ ជនជាប់សង្ស័យ

ជនសង្ស័យ ឬ ជនជាប់សង្ស័យត្រូវបានប្រើក្នុងដំណាក់កាលដំបូងនៃនីតិវិធី នៅពេលដែលជនម្នាក់ត្រូវបានឃាត់ខ្លួនដោយនគរបាលយុត្តិធម៌ ។ ដំណាក់ដំបូងនៃនីតិវិធី គឺដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តធម៌ទាំងការស៊ើបអង្កេតបឋម និងការស៊ើបអង្កេតករណីជាក់ស្តែង ដើម្បីសំគាល់ជនទាំងឡាយដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ។ ពាក្យជនសង្ស័យ ឬ ជនជាប់សង្ស័យ ត្រូវបានគេប្រើរហូតដល់ពេលដែលចៅក្រមស៊ើបសួរសម្រេចដាក់ជននេះឱ្យស្ថិតនៅក្រោមការពិនិត្យ ឬ រហូតដល់ពេលព្រះរាជអាជ្ញាសម្រេចបញ្ជូនជននេះទៅជំនុំជម្រះ ។

### ២.២.២ ជនត្រូវចោទ

ជនត្រូវចោទត្រូវបានប្រើក្នុងដំណាក់កាលនៃស៊ើបសួរ គឺចាប់ពីពេលបើកការស៊ើបសួរ រហូតដល់ពេលបិទបញ្ចប់ការស៊ើបសួរ ឬ ក៏យើងកំណត់ថានៅពេលដែលអយ្យការបានចាប់ផ្តើមចោទប្រកាន់ នោះជនសង្ស័យប្រែក្លាយទៅជាជនត្រូវចោទ ។ ពាក្យជនត្រូវចោទត្រូវបានប្រើប្រាស់រហូតដល់ជននេះត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះមុខតុលាការ ។

### ២.២.៣ ជនជាប់ចោទ

ជនជាប់ចោទត្រូវបានប្រើនៅពេលដែលមានការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ដោយព្រះរាជអាជ្ញាតាមកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម និងតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ នៅពេលដែលចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរសម្រេចបិទបញ្ចប់ការស៊ើបសួរដោយការបញ្ជូនទៅជំនុំជម្រះចំពោះមុខតុលាការ[42] ។ វាក្យស័ព្ទនេះក៏ត្រូវបានប្រើផងដែរ នៅក្រោយពេលដែលជនទាំងឡាយដែលត្រូវបានតុលាការផ្តន្ទាទោសរួច (ពិរុទ្ធជន) បានធ្វើការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខជននោះ ឬ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមផ្តន្ទាទោសជននោះ ឬ ក៏ប្តឹងសារទុក្ខប្រឆាំងនឹងសាលដីកាផ្តន្ទាទោសជននោះ ។

[41] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម កើត រិទ្ធ ឆ្នាំ២០១៦ ទំព័រ ១៣ ។

[42] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

### ២.២.៤ ពិរុទ្ធជន

ពិរុទ្ធជនត្រូវបានគេយកទៅប្រើសម្រាប់សម្គាល់ដល់ជនជាប់ចោទទាំងឡាយ ដែលត្រូវបានតុលាការសម្រេចធ្វើការផ្តន្ទាទោស[43] ។ វាក្យស័ព្ទនេះក៏ត្រូវបានប្រើផងដែរ ចាប់ពីពេលដែលជនជាប់ចោទត្រូវបានតុលាការសម្រេចផ្តន្ទាទោសរហូតដល់ពេលដែលជននោះបានធ្វើការប្តឹងតវ៉ានឹងសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោសនោះ ឬ រហូតដល់ពេលដែលសាលក្រម ឬ សាលដីកានោះបានចូលជាស្ថាពរ ។

### ២.២.៥ ទណ្ឌិត

ទណ្ឌិតត្រូវបានគេយកទៅប្រើនៅពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ដើម្បីសម្គាល់ជនជាប់ចោទដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោស ។ ហើយវាក្យស័ព្ទទណ្ឌិតនេះត្រូវបានគេប្រើរហូត ទោះបីមានការប្តឹងសើរើក៏ដោយ មានន័យថាក្រោយពេលប្តឹងសើរើ គឺមិនត្រូវប្រើពាក្យថាជនជាប់ចោទជំនួសពាក្យទណ្ឌិតនោះដូចជានៅក្នុងករណីពិរុទ្ធជនប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍ ឬ ប្តឹងសាទុក្ខឡើយ ។

## ២.៣ ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីអាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួនកាលណាជនរងគ្រោះនេះជាអនីតិជន ឬ ជានីតិជន ដែលស្ថិតនៅក្រោមច្បាប់ការពារ[44] ។ ដើម្បីអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ចាំបាច់ត្រូវមានផលប្រយោជន៍ ពោល គឺជាជនដែលទទួលរងនូវការខូចខាតនូវព្យសនកម្ម ដែលព្យសនកម្មត្រូវតែពិតប្រាកដ និងដោយផ្ទាល់ ។

គួរកត់សម្គាល់ថា សមាគមមួយចំនួនក៏ត្រូវបានអនុញ្ញាតឱ្យតាំងខ្លួនជាដើមរដ្ឋប្បវេណីដែរ ដូចជាសមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងសមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង[45] ។ ប៉ុន្តែ ដើម្បីឱ្យបណ្តឹងនោះអាចទទួលយកបាន គឺត្រូវគោរពលក្ខខណ្ឌ ដូចជាត្រូវតែមានភស្តុតាងបញ្ជាក់ថាបានទទួលការយល់ព្រមពីសិទ្ធិពីជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់នៃជននេះ ។ ក្នុងករណីបៀតបៀនដល់អាយុជីវិត បណ្តឹងរបស់សមាគមអាចទទួលយកបានលុះត្រាតែ សមាគមបានបង្ហាញភស្តុតាងបញ្ជាក់ថាបានទទួលការយល់ព្រមពីសិទ្ធិពីសិទ្ធិវន្តនៃជនរងគ្រោះ[46] ។

## ២.៤ អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាជនទាំងឡាយដែលច្បាប់តម្រូវឱ្យទទួលខុសត្រូវអំពើរបស់អ្នកដទៃដែលជាជនជាប់ចោទនៅក្នុងនីតិវិធីព្រហ្មទណ្ឌ[47] ។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចជា៖

- ឪពុកម្តាយ ឬ អាណាព្យាបាលរបស់ជនល្មើសដែលជាអនីតិជន
- អ្នកមានសិទ្ធិជាអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈរបស់ជនល្មើស

[43] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[44] មាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[45] មាត្រា ១៧ មាត្រា ១៨ និងមាត្រា ១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[46] មាត្រា ២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[47] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រទី១០ ។

- សិទ្ធវ័ន្តរបស់ជនល្មើស
- និយោជិករបស់ជនល្មើស
- ក្រុមហ៊ុមធានារ៉ាប់រង ។

# ជំពូកទី២
# ដំណើរការនៃបណ្តឹងអាជ្ញាក្នុងនីតិវិធីតុលាការ

## ផ្នែកទី១៖ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញា

ជាទូទៅ បណ្តឹងមួយអាចដំណើរការទៅបានឈានទៅដល់ការជំនុំជម្រះ និងធ្វើសេចក្តីសម្រេចបាន គឺត្រូវមានការចាប់ផ្តើមនៃការដាក់បណ្តឹងពីភាគីដែលពាក់ព័ន្ធជាមុនសិន ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីការចាប់ផ្តើមនៃបណ្តឹងអាជ្ញាដោយអយ្យការ និងការដាក់បណ្តឹងឱ្យមានចលនាដោយជនរងគ្រោះ ។

### ១.១ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយតំណាងអយ្យការ

បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលមានគោលបំណងក្នុងការការពារផលប្រយោជន៍សង្គម ដែលធ្វើឡើងប្រឆាំងបុគ្គលណាដែលប្រព្រឹត្តបទល្មើស និងផ្តន្ទាទោសចំពោះជនដែលល្មើសច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌ ។

មានតែអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[48] ។ នេះមានន័យថា នៅក្នុងស្ថាប័នយុត្តាធិការ គឺមានតែតួអង្គអយ្យការមួយប៉ុណ្ណោះដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ដើម្បីចោទប្រកាន់ទៅលើជនណាមួយដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។

អង្គការអយ្យការ គឺជាស្ថាប័នដែលធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ ត្រង់នេះអាចនិយាយបានថា មានតែស្ថាប័នអយ្យការមួយគត់ គឺជាអ្នកដែលចាប់ផ្តើមនៃបណ្តឹងអាជ្ញា ដែលបណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការក្នុងការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[49] ។

### ១.២. ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ

ជនរងគ្រោះសំដៅទៅដល់បុគ្គលដែលទទួលរងគ្រោះដោយផ្ទាល់ពីអំពើល្មើសរបស់ជន ដែលប្រព្រឹត្តបទល្មើស ។ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ បុគ្គលដែលប្រកាសខ្លួនថាជាជនរងគ្រោះនៃបទល្មើសអាចមានសិទ្ធិដាក់ពាក្យប្តឹងបាន តាមរយៈការដាក់ពាក្យប្តឹងនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬ អាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅស្ថាប័នតុលាការដែលមានសមត្ថកិច្ចដោះស្រាយ និងជំនុំជម្រះ ។ ជាធម្មតា ចំពោះរឿងក្តីព្រហ្មទណ្ឌដែលទើបតែចាប់ផ្តើមដំណើរការ គឺស្ថិតក្នុងសមត្ថកិច្ចសាលាដំបូងរាជធានី-ខេត្ត ។

ពាក្យប្តឹងពីសំណាក់ប្រជាពលរដ្ឋ ដែលជាជនរងគ្រោះអំពីបទល្មើសព្រហ្មទណ្ឌអាចជាពាក្យប្តឹងសាមញ្ញ ឬ ក៏ពាក្យប្តឹងដែលមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែ បើករណីដែលបណ្តឹងត្រូវបានតម្កល់រឿងទុកឥតចាត់ការ នោះជនរងគ្រោះក៏នៅតែមានសិទ្ធិប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[50] ។

ជាធម្មតា នៅពេលណាដែលមានបទល្មើសកើតឡើង គឺអាចមាការដាក់នូវបណ្តឹងអាជ្ញាអោយមានចលនា ។ ចំពោះការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជាយើងវិញ គឺគេមិនសូវឃើញជនរងគ្រោះជាអ្នកដាក់បណ្តឹងអាជ្ញា ឬ ការបញ្ជូនសំណុំរឿងនៃបទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែងពីអាជ្ញាធរសាធារណៈទៅកាន់អយ្យការ ឬ ចៅក្រមស៊ើបសួរឡើយ ។

[48] មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

[49] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[50] មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

ការដាក់បណ្តឹងដោយជនរងគ្រោះអាចមានលក្ខណៈប្រថុយប្រថាន កាលណាមានបណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា ។ វាកើតឡើងនៅពេលដែលបន្ទាប់ពីមានពាក្យប្តឹងដោយជនរងគ្រោះតាំងនាមជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបិទតាមដីកាលើកលែងចោទប្រកាន់ ឬ ពេលចៅក្រមស៊ើបសួរយល់ថានីតិវិធីធ្វើឡើងដោយរំលោភ ឬ អូសបន្លាយពេលវេលា នៅពេលនោះចៅក្រមស៊ើបសួរអាចសម្រេចនាំអោយដើមបណ្តឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី[51] ។ ករណីហានិភ័យមួយទៀត គឺការដាក់បណ្តឹងដោយជនរងគ្រោះ កាលណាមានការដាក់បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា ឬ ដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ នោះអ្នកដែលមានឈ្មោះនៅក្នុងបណ្តឹងអាចនឹងប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងខ្លួន[52] ។

### ១.២.១ ការដាក់ពាក្យប្តឹងតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ

មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ ឬ បណ្តឹងបរិហារ[53] ។ គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌តម្រូវឱ្យធ្វើកំណត់ហេតុ[54] ។ ពេលបទល្មើសកើតឡើង យើងអាចដាក់ពាក្យបណ្តឹងទៅស្ថាប័ន ឬ អង្គភាពណាដែលច្បាប់ផ្តល់សម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដែលវាអាស្រ័យទៅតាមប្រភេទបទល្មើស និងសម្បទារបស់មន្ត្រីនគរបាលយុត្តិធម៌នោះ[55] ។ តែជាការងាយស្រួល យើងអាចដាក់បណ្តឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌នៅមូលដ្ឋានជិតបំផុត ហើយក៏អាចដាក់បណ្តឹងទៅកាន់អយ្យការអមសាលាដំបូងដោយផ្ទាល់ផងដែរ ។

ករណីមួយទៀត បើទោះបីជាជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹងក៏ដោយ តែមន្ត្រីនគរបាលយុត្តិធម៌បានដឹងពីព័ត៌មាននៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយផ្ទាល់ ឬ ដោយប្រយោលក្តី ក៏មន្ត្រីនគរបាលយុត្តិធម៌អាចចាប់ផ្តើមនីតិវិធីដូចបានទទួលពាក្យប្តឹងពីជនរងគ្រោះផងដែរ ។

### ១.២.២ ការដាក់ពាក្យប្តឹងនៅចំពោះមុខចៅក្រមស៊ើបសួរ

តាមគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺអនុញ្ញាតអោយជនរងគ្រោះអាចដាក់បណ្តឹង ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិមអាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា ដើម្បីអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងជនរងគ្រោះត្រូវតម្កល់ប្រាក់ទុកស្របតាមនីតិវិធីនៃមាត្រា១៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ[56] ។ ពាក្យប្តឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី[57] ។ ដើម្បីអោយមេធាវីអាចតំណាងអោយជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់ពាក្យប្តឹងទៅអយ្យការ ឬ នៅចំពោះមុខចៅក្រមស៊ើបសួរបាន គឺត្រូវមាន

[51] មាត្រា ១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[52] មាត្រា ១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[53] មាត្រា ៧១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[54] មាត្រា ៧២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[55] មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[56] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[57] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

លិខិតប្រគល់សិទ្ធិប្ដឹងទាមទារសំណង[58] ។ បន្ទាប់មកចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងនោះរបស់ជនរងគ្រោះទៅព្រះរាជអាជ្ញា ។

### ១.២.៣ របៀបនៃការសរសេរបណ្ដឹង

បណ្ដឹងក្នុងរឿងព្រហ្មទណ្ឌត្រូវសរសេរដោយទម្រង់មួយដែលត្រូវមានៈ

- ឈ្មោះ អត្តសញ្ញាណ មុខរបរ លំនៅរបស់ជនរងគ្រោះ ឬ ដើមបណ្ដឹង ។
- ស្ថាប័ន ឬ អង្គភាពដែលជនរងគ្រោះ ឬ ដើមបណ្ដឹងត្រូវដាក់បណ្ដឹងទៅ ។
- កម្មវត្ថុនៃបណ្ដឹងដែលជនរងគ្រោះ ឬ ដើមបណ្ដឹងស្នើសុំពីបទល្មើសដែលជនសង្ស័យប្រព្រឹត្តមកលើខ្លួន ញាតិ ឬ ក្រុមគ្រួសារ ។
- អង្គហេតុដែលកើតឡើងតាំងពីដើមរហូតដល់កើតបទល្មើស ដែលត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីសមត្ថកិច្ចងាយកំណត់នូវបទល្មើសដែលបានប្រព្រឹត្ត ។
- សំណូមពរ គឺត្រូវស្នើសុំនូវចំណុចពាក់ព័ន្ធគោលបំណងនៃការធ្វើបណ្ដឹងដែលអាចប្ដឹង ទាំងបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណីពីការទាមទារពាក់ព័ន្ធបទល្មើស ។
- ជនរងគ្រោះ ឬ ដើមបណ្ដឹងត្រូវផ្ដិតមេដៃស្ដាំលើបណ្ដឹងរបស់ខ្លួនដែលបានបំពេញតាមចំណុចដូចរៀបរាប់ខាងលើ ។

បណ្ដឹងក្នុងរឿងព្រហ្មទណ្ឌត្រូវអនុវត្តតាមទម្រង់ខាងលើ ដើម្បីមានលក្ខណៈពេញលេញតាមផ្លូវច្បាប់ ។ ក៏ប៉ុន្តែ ក្នុងករណីមានបទល្មើសណាមួយកើតឡើង ជនរងគ្រោះ ឬ ដើមបណ្ដឹងក៏អាចស្នើសុំឱ្យសមត្ថកិច្ចជួយសរសេរបណ្ដឹង ឬ អាចពឹងមេធាវីឱ្យរៀបចំធ្វើបណ្ដឹង ដើម្បីការពារផលប្រយោជន៍របស់ខ្លួនបានដែរ ។

ពាក្យប្ដឹងសាមញ្ញគ្មានអានុភាពនាំឱ្យធ្វើជាការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ[59] ។ ប៉ុន្តែ សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ លោកត្រូវទទួលចាត់ការរាល់បណ្ដឹងទាំងអស់ បើទោះបីជាក្នុងករណីសរសេរពុំត្រឹមត្រូវតាមទម្រង់ក៏ដោយ ។ សមត្ថកិច្ចអាចណែនាំក្នុងការសរសេរ ឬ ក៏ចង្អុលបង្ហាញឱ្យពឹងពាក់មេធាវី ដើម្បីជួយរៀបចំ ។

## ផ្នែកទី២ ចំណាត់ការលើពាក្យប្ដឹងក្នុងរឿងព្រហ្មទណ្ឌ

ដំណើររឿងក្ដីព្រហ្មទណ្ឌនៅសាលាក្ដីជាន់ទាបត្រូវបានបែងចែកជា ៤ ដំណាក់កាល គឺដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ។ ការចាប់ផ្ដើមធ្វើឱ្យមានដំណើរការនៃបណ្ដឹងអាជ្ញាមួយ គឺធ្វើឡើងដោយស្ថាប័នអយ្យការ ដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងត្រូវអនុវត្តនីតិវិធីជាច្រើនក្នុងការបង្កើតឡើងនូវបណ្ដឹងតាមរយៈការចោទប្រកាន់របស់ខ្លួន ។

[58] មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[59] មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

## ២.១ ចំណាត់ការលើពាក្យប្តឹងក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងអាជ្ញាត្រូវចាប់ផ្តើមភ្លាមៗដោយធ្វើការស៊ើបអង្កេត ឬ ក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីបន្តនីតិវិធី[60] ។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យប្តឹងពីជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ឬ តតិយជន ពីករណីព្រហ្មទណ្ឌណាមួយនោះពួកគាត់ត្រូវចាប់ផ្តើមនីតិវិធីភ្លាមដោយៈ

- បើកការស៊ើបអង្កេត
- ចុះទៅកន្លែងកើតហេតុ (តាមរយៈសាក្សី ឬ ជនរងគ្រោះ ។ល។)
- ធ្វើការកំណត់អត្តសញ្ញាណជនល្មើស
- ធ្វើសេចក្តីសន្និដ្ឋានបញ្ជូនទៅការិយាល័យអយ្យការដើម្បីត្រៀមធ្វើការចោទប្រកាន់ ។

ក្នុងករណីបណ្តឹងបានដាក់ហើយ ក៏ប៉ុន្តែពុំទាន់មានចំណាត់ការណាមួយ មន្ត្រីនគរបាលយុត្តិធម៌លោកត្រូវពិនិត្យចាត់ការស៊ើបអង្កេតស្រាវជ្រាវករណីនេះ ។ ក៏ប៉ុន្តែ ក្នុងករណីណាមួយដែលមានការយឺតយ៉ាវ ឬ ពុំមានការចាត់ការ ដោយសារមន្ត្រីនគរបាលយុត្តិធម៌ជាប់បេសកកម្ម នោះដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ដែលទទួលបានការការពារដោយច្បាប់ ជនរងគ្រោះ ឬ ដើមបណ្តឹងអាចដាក់ពាក្យប្តឹងជាថ្មីមកព្រះរាជអាជ្ញាអមសាលាដំបូង ដែលនឹងបង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងដែលបានស៊ើបអង្កេតមកកាន់អយ្យការអមសាលាដំបូងដើម្បីពិនិត្យចាត់ការបន្ត និងឈានទៅដល់ការសម្រេចដល់ការបើកការស៊ើបសួរ (ចោទប្រកាន់) ទៅចៅក្រមស៊ើបសួរបន្តទៀត ។

ក្នុងពេលបណ្តឹងកំពុងចាត់ការដោយមន្ត្រីនគរបាលយុត្តិធម៌ ជនរងគ្រោះ ឬ ដើមបណ្តឹងបានទទួលសំណងណាមួយពីជនសង្ស័យ ហើយសុំដកពាក្យប្តឹងវិញ ក្នុងករណីនេះ ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណីអាចដកពាក្យប្តឹងរដ្ឋប្បវេណី ក្នុងការទាមទារសំណងពីជនសង្ស័យតែប៉ុណ្ណោះ ។ ចំពោះបណ្តឹងអាជ្ញា សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ត្រូវបន្តចាត់ការបញ្ជូនសំណុំរឿងទៅអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ច ដោយមិនអាចតម្កល់សំណុំរឿងណាមួយទុកឥតចាត់ការបានឡើយ[61] ។

## ២.២ ចំណាត់ការលើបណ្តឹងក្នុងដំណាក់កាលអយ្យការ

អយ្យការ គឺជាស្ថាប័នដែលមានសិទ្ធិធ្វើការចោទប្រកាន់ពីបណ្តឹងអាជ្ញា ។ គោលការណ៍កាលានុវត្តនៃបណ្តឹង ឬ ជនល្មើសនៃការចោទប្រកាន់នៃបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាថ្លឹងថ្លែងលើចំណាត់ការលើបណ្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។ ព្រះរាជអាជ្ញាចាប់ផ្តើមស៊ើបអង្កេតបឋម ឬ ស្រាវជ្រាវបន្ថែមជាមុនសិន មុននឹងសម្រេចថាតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់[62] ។

[60] មាត្រា ៧៤ វាក្យខណ្ឌ ទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[61] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[62] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

### ២.២.១ ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជាជម្រើសមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញា ។ ការសម្រេចនេះត្រូវសំអាងច្បាប់ និងសំអាងហេតុឱ្យបានត្រឹមត្រូវ ។

#### ២.២.១.១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយឆន្ទានុសិទ្ធិ តាមរយៈការថ្លឹងថ្លែងរបស់ខ្លួន ប៉ុន្តែ ការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះត្រូវផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមស្របដែលមានដូចជា[63]៖

- កង្វះធាតុផ្សំនៃបទល្មើស៖ សំដៅដល់អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើស លុះត្រាតែមានធាតុផ្សំ ៣ គឺ៖ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ។
- អវត្តមាននៃបទល្មើស៖ សំដៅដល់សំណុំរឿងទាំងឡាយណាពុំមានបទល្មើសព្រហ្មទណ្ឌ ហើយដែលមិនមែនជាប្រភេទរឿងក្តីព្រហ្មទណ្ឌ ។
- មូលហេតុគតិយុត្ត៖ សំដៅដល់មូលហេតុច្បាប់ទាំងឡាយណាដែលបានបញ្ញត្តិរារាំងតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសបាន ។ មូលហេតុគតិយុត្ត រួមមានអភ័យឯកសិទ្ធិ អនិយ័តភាពនៃកិច្ចនីតិវិធី ការផុតរលត់នៃបណ្តឹងអាជ្ញា និងការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។
- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍៖ សំដៅដល់ការថ្លឹងថ្លែងរបស់តំណាងអយ្យការលើស្ថានភាពនានា ដែលពាក់ព័ន្ធបទល្មើស ចារី ជនរងគ្រោះ ជាអាទិ៍ ហើយរកឃើញថា ប្រសិនបើការចោទប្រកាន់ហាក់មិនបានផ្តល់ផលអ្វីសោះដល់សង្គម និងផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញា ។ មូលហេតុដែលនាំឱ្យការចោទប្រកាន់មិនផ្តល់ប្រយោជន៍ អាចបណ្តាលមកពីកត្តាផ្សេងៗដូចជា៖ កត្តាចំណាត់ការ កត្តាចារី កត្តាជនរងគ្រោះ កត្តាព្យសនកម្ម ជាអាទិ៍ ។

#### ២.២.១.២ នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

នីតិវិធីនៃការតម្កល់សម្រេចរឿងទុកឥតចាត់ការ អាចធ្វើការបែងចែកជា ៣ ដំណាក់កាលគឺ[64]៖

- ការស្រាវជ្រាវ៖ តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យស្រាវជ្រាវបន្ថែមមុននឹងសម្រេចថាតម្កល់រឿងទុកឥតចាត់ការ[65] ។
- ការសម្រេចតម្កល់រឿងទុកឥតចាត់ការ៖ បន្ទាប់ពីបានស្រាវជ្រាវបានចប់សព្វគ្រប់ ហើយយល់ឃើញថាត្រូវតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការនឹងធ្វើការសម្រេចដោយចេញសាលដីកាមួយឈ្មោះថាដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។
- ការជូនដំណឹង៖ បន្ទាប់ពីចេញសាលដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវជូនដំណឹងទៅអ្នកប្តឹងអំពីសេចក្តីសម្រេចឱ្យបានឆាប់បំផុត ហើយយ៉ាងយូរបំផុត ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលពាក្យប្តឹងចុះបញ្ជី ។

[63] ស្លាយមេរៀន ស្តីពី ការតម្កល់ទុករឿងឥតចាត់ការ រៀបរៀងដោយ ន.ស.រ ឆ្នាំ ២០០៧ ទំព័រ ៩ ដល់ទំព័រ ២៤ ។

[64] ស្លាយមេរៀន ស្តីពី ការតម្កល់ទុករឿងឥតចាត់ការ រៀបរៀងដោយ ន.ស.រ ឆ្នាំ ២០០៧ ទំព័រ ២៥ ដល់ទំព័រ ២៧ ។

[65] មាត្រា ៤០ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

ការតម្កល់រឿងទុកឥតចាត់ការ គឺពុំមានអានុភាពអាជ្ញាអស់ជំនុំនោះឡើយ[66] ។ តាមគោលការណ៍អាជ្ញាអស់ជំនុំ ជនដែលត្រូវតុលាការផ្តន្ទាទោសឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ[67] ។ ដូច្នេះ ព្រះរាជអាជ្ញាអាចសម្រេចបើកការស៊ើបអង្កេតឡើងវិញ ប្រសិនបើខ្លួនយល់ថាមានការផ្លាស់ប្តូរស្ថានភាពដែលនាំឱ្យការតម្កល់រឿងទុកឥតចាត់ការនោះ ហើយកាលបើបណ្តឹងអាជ្ញានៅមិនទាន់ផុតរលត់នៅឡើយ ។

## ២.២.១.៣ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ

យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ គឺសំដៅដល់នីតិវិធីទាំងឡាយដែលធ្វើឡើង ដើម្បីនាំឱ្យមានការចោទប្រកាន់ឡើងវិញ បន្ទាប់ពីមានការតម្កល់រឿងទុកឥតចាត់ការ ។

យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញមានចំនួន៤ គឺ ៖

- ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ៖ ប្រសិនបើអយ្យការយល់ឃើញថាអំពើល្មើសមានធាតុផ្សំគ្រប់គ្រាន់ ឬ មានភស្តុតាងថ្មីដែលអាចបញ្ជាក់ពីរឿងហេតុ នោះតំណាងអយ្យការអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន ក្នុងករណីបណ្តឹងអាជ្ញានោះមិនទាន់រលត់[68] ។
- ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖ ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាតាមបណ្តឹងសាមញ្ញក្នុងរយៈពេល២ខែ គិតពីថ្ងៃទទួលដំណឹងពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចេញអធិបញ្ញាដែលធ្វើឡើងជាលាយលក្ខណ៍អក្សរដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់ ប្រសិនបើការតវ៉ាមានមូលហេតុត្រឹមត្រូវ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ដោយមានការជូនដំណឹងពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា[69] ។
- ការធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ៖ ដោយអង្គការអយ្យការជាអង្គភាពដែលត្រូវស្ថិតនូវក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមនាយឋានានុក្រមរបស់ខ្លួន ដែលមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[70] ។
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ[71] ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងទៅដល់ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា ។ ចៅក្រមស៊ើបសួរធ្វើការកត់

[66] មាត្រា ៤១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[67] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[68] មាត្រា ៤១ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[69] មាត្រា ៤១ វាក្យខណ្ឌទី៥-៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[70] មាត្រា ៧៥ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ។

[71] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

សម្គាល់នូវការដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា និងធ្វើការបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា[72] ។

### ២.២.២ កាលានុវត្តភាពនៃការចោទប្រកាន់

ការអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង នីតិវិធីដែលរួចរាល់អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬ ផ្ទុយទៅវិញ តម្រូវឱ្យមានការស៊ើបសួរទូលំទូលាយ ពោល គឺអាចប្តឹងទៅយុត្តាធិការជំនុំជម្រះ ឬ ប្តឹងទៅយុត្តាធិការស៊ើបសួរ ។ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បណ្តឹងអាជ្ញាតាមមធ្យោបាយពីរ គឺការប្តឹងទៅយុត្តាធិការស៊ើបសួរ គឺការបើកការស៊ើបសួរ និងការប្តឹងទៅយុត្តាធិការជំនុំជម្រះ ដែលអាចប្តឹងតាមរបៀបពីរ គឺការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម ។

#### ២.២.២.១ ការបើកការស៊ើបសួរ

ព្រះរាជអាជ្ញាអាចមានជម្រើសពីរ គឺបន្តការស៊ើបអង្កេត និងធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ ។ ព្រះរាជអាជ្ញាជាអ្នកបើកការស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងអោយស៊ើបសួរ ដែលប្តឹងទៅចៅក្រមស៊ើបសួរ ។ ការបើកការស៊ើបសួរអាចប្រឆាំងនឹងបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញត្តិជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះនៃបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន
- ត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវចាត់ទុកជាមោឃៈ[73] ។

ការបើកការស៊ើបសួរមានលក្ខណៈដាច់ខាត ក្នុងករណីដែលបទល្មើសដែលនឹងអាចធ្វើការចោទប្រកាន់នោះមានបទល្មើសមួយជាចម្បងជាបទឧក្រិដ្ឋ ប៉ុន្តែ ការបើកការស៊ើបសួរមានលក្ខណៈមិនដាច់ខាតនោះទេចំពោះបទល្មើសដែលនឹងអាចចោទប្រកាន់ជាបទមជ្ឈិម និងបទលហុ[74] ។

ប្រសិនបើ ចៅក្រមស៊ើបសួរទទួលពាក្យប្តឹងសាមញ្ញ គឺត្រូវបញ្ជូនពាក្យប្តឹងនោះទៅព្រះរាជអាជ្ញា ។ ប្រសិនបើ ចៅក្រមស៊ើបសួរទទួលបានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នោះចៅក្រមស៊ើបសួរអាចប្តឹងទៅព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។ ក្នុងករណីចុងក្រោយនេះ ស្ថាប័នអយ្យការធ្វើការបើកការស៊ើបសួរ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងនីតិវិធីជាអាទិ៍ នៅពេលដែលបុគ្គលដែលជាប់ពាក់ព័ន្ធមិនបានកំណត់ពីអត្តសញ្ញាណ និងមិនអាចកំណត់បានក្នុងពេលបច្ចុប្បន្ន ។

[72] មាត្រា ១២៤ វាក្យខណ្ឌទី៤ និងទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[73] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

មួយវិញទៀត ព្រះរាជអាជ្ញាក៏សម្រេចបើកការស៊ើបសួរផងដែរ កាលបើយល់ឃើញថាភស្តុតាងដែលប្រមូលបានពុំទាន់គ្រប់គ្រាន់ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតនោះមិនអាចប្រមូលបានដោយការស៊ើបអង្កេតបឋម ប៉ុន្តែ អាចប្រមូលមកបានលុះត្រាតែប្រើអំណាចដោយបង្ខំ ឬ បទល្មើសមជ្ឈិមដែលត្រូវពិគ្រោះនោះមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឱ្យមានការស្រាវជ្រាវយូរ និងប្រកបដោយភាពពិបាក ។

### ២.២.២.២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងដំណាក់កាលនេះ កាលបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងនីតិវិធីអាចបញ្ជូនទៅតុលាការជំនុំជម្រះ ដោយពុំចាំបាច់មានការស្រាវជ្រាវផ្សេងទៀត ។ ព្រះរាជអាជ្ញាអាចសម្រេចឱ្យបុគ្គលដែលពាក់ព័ន្ធមកបង្ហាញខ្លួននៅចំពោះមុខដើម្បីធ្វើការចោទប្រកាន់ភ្លាមៗ គឺការចូលបង្ហាញខ្លួនភ្លាម ឬ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ប៉ុន្តែ នីតិវិធីបែបនេះមិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋនោះទេ ។

វិធីចំណាត់ការបែបនេះ អនុញ្ញាតឱ្យព្រះរាជអាជ្ញាប្តឹងដោយផ្ទាល់ទៅយុត្តាធិការជំនុំជម្រះ និងបង្គាប់ឱ្យជនជាប់ចោទបង្ហាញខ្លួននៅមុខសាលាដំបូង ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះអាចអនុវត្តចំពោះគ្រប់បទមជ្ឈិម និងបទលហុ តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជំម្រះផ្ទាល់ ។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន ៖

- អត្តសញ្ញាណជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនការ ។ ដីកានេះ ត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីអមខ្លួនបាន[75] ។

### ២.២.២.៣ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

វិធីចំណាត់ការបែបនេះអនុញ្ញាតឱ្យព្រះរាជអាជ្ញាបង្គាប់ឱ្យជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមៗ នៅមុខសាលាដំបូង បន្ទាប់ពីបញ្ចប់ការឃាត់ខ្លួន ប៉ុន្តែ វិធាននៃនីតិវិធីនេះមិនត្រូវបានអនុវត្តចំពោះបទលហុ និងបទមជ្ឈិមដែលប្រព្រឹត្តដោយអនីតិជនទេ[76] ។

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជាប់ចោទឱ្យចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ ៖

- បទល្មើសជាក់ស្តែង
- បទល្មើសផ្តន្ទាទោសពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ
- ជនជាប់ចោទជានីតិជន

[75] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[76] សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីហ្សា និង លោក ខាន់ សុខា ទំព័រទី ៤៥ ។

- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន[77] ។

ពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនដោយមានកម្លាំងការពារដើម្បីឱ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ។ បន្ទាប់ពីបានទទួលកំណត់ហេតុ និងខ្លួនបុគ្គលឃាត់ខ្លួនពីមន្ត្រីនគរបាលយុត្តិធម៌ កាលបើសម្រេចប្រើនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[78] ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថាខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ មេធាវីជ្រើសរើស ឬ ចាត់តាំងត្រូវបានទទួលដំណឹងភ្លាមព្រមទាំងអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។ ក្នុងរឿងព្រហ្មទណ្ឌ មេធាវីអាចជួយការពារជនជាប់ចោទ[79] ។

ទម្រង់ការទាំងនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ បើពុំនោះ នីតិវិធីត្រូវទុកជាមោឃៈ ។

ជនជាប់ចោទត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

សាលាដំបូងដែលទទួលបណ្តឹងតាមកំណត់ហេតុ ត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទដំបូងគេបង្អស់ និងធ្វើបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ និងជាពិសេសត្រូវប្រាប់ដល់ជននេះអំពីរយៈពេលដែលមានដើម្បីរៀបចំការពារខ្លួន ។ ប្រសិនបើ ជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ឬ បើតុលាការយល់ឃើញថារឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ នោះសំណុំរឿងត្រូវលើកទៅពេលសវនាការនាពេលក្រោយ ។ សវនាការនេះត្រូវបើកក្នុងចិរវេលាមិនអាចលើសពី ២ សប្តាហ៍បានឡើយ ។ ក្នុងរយៈពេលដែលរងចាំការបង្ហាញខ្លួន តុលាការត្រូវសម្រេចឃុំខ្លួនជនជាប់ចោទដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ និងយោងអំពីមូលហេតុនៃការឃុំខ្លួនជាបណ្តោះអាសន្នអនុលោមតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាបណ្តោះអាសន្នរហូតដល់ពេលសវនាការ ។ បន្ទាប់មក តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន យោងតាមអំណាចសាលក្រម ។ កាលបើរយៈពេល ២ (ពីរ) សប្តាហ៍គិតចាប់ពីពេលចូលទៅបង្ហាញខ្លួននៅមុខតុលាការកន្លងផុតទៅ សាលក្រមអង្គសេចក្តីនៅមិនទាន់បានប្រកាស នោះការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ។

ការអនុវត្តវិធាននៃនីតិវិធីបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា មិនមានអនុភាពកម្រិតឱ្យសាលាដំបូងត្រូវតែប្រតិបត្តិនោះទេ ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនីតិវធីព្រហ្មទណ្ឌមិនបានបំពេញទេ

[77] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[78] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[79] មាត្រា ២ វាក្យខណ្ឌទី២នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ ។

ឬ ក៏ដោយភាពសាំញ៉ាំនៃសំណុំរឿងតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម នោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ បើពុំដូច្នេះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

# ជំពូកទី៣
# ការរលត់បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាគឺជាប់ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ដែលអយ្យការអាចធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងបុគ្គលគ្រប់រូបដែលប្រកាសខ្លួនថាជាជនរងគ្រោះនៃបទល្មើស ក៏អាចដាក់ពាក្យប្តឹងបានដែរ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាអាចចាប់ផ្តើមដោយជនរងគ្រោះ តែប្រសិនបើករណី បទល្មើសព្រហ្មទណ្ឌនោះត្រូវបាន អយ្យការសម្រេចថាចោទប្រកាន់ហើយ នោះជនសង្ស័យ ឬ ជនជាប់សង្ស័យគឺត្រូវតែបញ្ជូនខ្លួនទៅជំនុំជម្រះ បើទោះបីជាជនរងគ្រោះចង់ដកពាក្យប្តឹងក៏ដោយ ។ បទល្មើសព្រហ្មទណ្ឌ គឺជាប់ទាក់ទងនឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈទាំងមូល ដូច្នេះ បើទោះបីជាគ្មានការដាក់ពាក្យប្តឹងពីជនរងគ្រោះ ឬ ជនរងគ្រោះចង់ដកពាក្យប្តឹងវិញ ក៏មិនអាចជាមូលហេតុធ្វើឱ្យមានការរលត់បណ្តឹងអាជ្ញាបានដែរ ។

កាលណា បណ្តឹងអាជ្ញារលត់ ការចោទប្រកាន់លើបណ្តឹងអាជ្ញា គឺមិនអាចចាប់ផ្តើមបានទេ ហើយប្រសិនបើ បណ្តឹងអាជ្ញាកំពុងស្ថិតក្នុងនីតិវិធីតុលាការគឺត្រូវបញ្ឈប់ភ្លាមៗ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ គឺបានចែងយ៉ាងច្បាស់អំពីមូលហេតុដែលធ្វើឱ្យមានការរលត់បណ្តឹងអាជ្ញាដែលរួមមានការរលត់ដោយមូលហេតុទូទៅ និងមូលហេតុផ្សេងទៀត ។

## ផ្នែកទី១៖ មូលហេតុទូទៅនៃការរលត់នៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាគឺអាចត្រូវបានរលត់ ក្នុងករណីដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[80] ។

### ១.១ មរណភាពនៃជនល្មើស

បណ្តឹងអាជ្ញាគឺមានគោលបំណងផ្តន្ទាទោសជនល្មើសតាមច្បាប់បានកំណត់ ។ ក្នុងករណីដែលជនល្មើសបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ រួចជនល្មើសបានទទួលមរណៈភាពមុនពេលមានបណ្តឹងអាជ្ញា ឬ កំឡុងពេលដំណើរការនៃបណ្តឹងអាជ្ញាដែលមិនទាន់មានសេចក្តីសម្រេចផ្តន្ទាទោសជនល្មើស នោះបណ្តឹងអាជ្ញាត្រូវរលត់ ។ មរណភាពនៃជនល្មើសមិនផ្តល់ផលប្រយោជន៍ដល់ សហចារី ឬ អ្នកសមគំនិត ឬ អ្នកផ្តើមគំនិត និងមិនអាចបង្កជាបញ្ហាដល់ការរឹបអូសនានាដែលអាចត្រូវបានធ្វើនៅក្នុងពេលដំណើរការនីតិវិធីឡើយ[81] ។

ថ្វីត្បិតតែ បណ្តឹងអាជ្ញាត្រូវរលត់នៅពេលជនល្មើសទទួលមរណៈភាព តែដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើ ជនជាប់ចោទនេះទទួលមរណៈភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ជាងនេះទៅទៀត តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តបុគ្គលទាំងនោះ[82] ។

[80] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[81] ឯកសារមេរៀន នីតិវិធីព្រហ្មទណ្ឌកម្ពុជា រៀបរៀងដោយ ចក សម្បត្តិ អនុប្រធានសមាគមត្រាជូ ទំព័រ ៨៧ ។

[82] មាត្រា ២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

## ១.២ ការផុតអាជ្ញាយុកាល

នៅក្នុងបទល្មើសព្រហ្មទណ្ឌ គឺបានបែងចែកអាជ្ញាយុកាលជាពីរ គឺអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និង អាជ្ញាយុកាលនៃទោស។

### ១.២.១ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាគឺជារយៈពេលកំណត់មួយដែលបណ្តឹងអាជ្ញាអាចធ្វើឡើងបាន ។ បើផុត រយៈពេលកំណត់នេះ គេលែងអាចធ្វើការចោទប្រកាន់ និងកាត់ទោសជនល្មើសបានទៀតហើយ ។ អាជ្ញា យុកាលនៃបណ្តឹងអាជ្ញា គឺត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសៈ

- ១៥ឆ្នាំ សម្រាប់បទឧក្រិដ្ឋ
- ៥ឆ្នាំ សម្រាប់បទមជ្ឈិម
- ១ឆ្នាំ សម្រាប់បទលហុ[83] ។

គួរកត់សម្គាល់ថា អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានេះត្រូវគិតចាប់ពីពេលដែលអំពើល្មើសត្រូវបានប្រព្រឹត្ត ដោយជនល្មើស ។

ឧទាហរណ៍ៈ បុគ្គលឈ្មោះ "ក" បានលួចទ្រព្យសម្បត្តិរបស់គេ ដែលជាបទមជ្ឈិម ក៏ប៉ុន្តែ គ្មានបណ្តឹង គ្មានការស៊ើបអង្កេត គ្មានការចោទប្រកាន់អ្វីទាំងអស់ ។ ៥ឆ្នាំ ក្រោយថ្ងៃដែល "ក" បានប្រព្រឹត្តអំពើល្មើស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាត្រូវផុត ដូច្នេះ តុលាការលែងអាចយកជនល្មើស "ក" នេះមកជំនុំជម្រះបានទៀត ហើយ ។

មានប្រភេទបទល្មើសធំៗមួយចំនួន រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាប្រភេទបទឧក្រិដ្ឋដែលគ្មានអាជ្ញាយុកាលទេ[84] ។ មានន័យថា បើទោះបីជា នៅក្រោយពេលប្រព្រឹត្តអំពើល្មើសប៉ុន្មានឆ្នាំក៏ដោយ ក៏តុលាការអាចយកជនល្មើសមកកាត់ទោសបានដែរ ។

ទាក់ទងនឹងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ឧបមាថា នៅសល់តែពីរ-បីថ្ងៃ មុនពេលផុតអាជ្ញាយុកាល ទើបគេចាប់ផ្តើមមានតម្រុយអំពីជនសង្ស័យ ហើយចាប់ផ្តើមបើកការស៊ើបអង្កេត ។ ក៏ប៉ុន្តែ ការស៊ើបអង្កេតត្រូវ ចំណាយពេលជាច្រើនខែ ។ ទម្រាំតែស៊ើបអង្កេតចប់ អាជ្ញាយុកាលក៏ត្រូវផុត ។ ក្នុងករណីនេះ តុលាការនៅតែ អាចយកជនល្មើសមកកាត់ទោសបាន ពីព្រោះថាអាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ[85] ។ មានន័យថា ឱ្យតែមានការចោទប្រកាន់ ឬ ការបើកការស៊ើបអង្កេតលើបទល្មើសណាមួយ ហើយអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាលើបទល្មើសនោះនឹងត្រូវផ្តាច់លែងរាប់តទៅទៀតហើយ ។

សរុបមកវិញ ទោះបីជានៅសល់ត្រឹមតែ១ថ្ងៃទៀតត្រូវផុតអាជ្ញាយុកាលក៏ដោយ ឱ្យតែមានការបើក ការស៊ើបអង្កេត អាជ្ញាយុកាលនឹងត្រូវផ្តាច់លែងរាប់តទៅទៀត ហើយទោះបីការស៊ើបអង្កេតនេះត្រូវចំណាយ ពេលរាប់ខែក៏ដោយ បើសិនជាមានសំណុំរឿងគ្រប់គ្រាន់ តុលាការនៅតែអាចធ្វើការចោទប្រកាន់ និងជំនុំជម្រះ ជនល្មើស ដោយបទល្មើសនេះមិនត្រូវផុតអាជ្ញាយុកាលនោះទេ ។

[83] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[84] មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។
[85] មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

#### ១.២.២ អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោសគឺទាក់ទងនឹងរយៈពេលដែលត្រូវអនុវត្តទោស មានន័យថា ក្នុងករណី ដែល ជនល្មើសត្រូវបានតុលាការកាត់ឱ្យជាប់ទោសរួចហើយ ប៉ុន្តែ គេមិនអាចចាប់ពិរុទ្ធជននេះឱ្យមកអនុវត្តទោសបាន ។ ដល់ផុតអាជ្ញាយុកាល ទោសនេះលែងអាចអនុវត្តទៀតបានហើយ ពោល គឺពិរុទ្ធជនត្រូវរួចខ្លួន។

អាជ្ញាយុកាលនៃទោស ក៏ត្រូវបែងចែកទៅតាមចំណាត់ថ្នាក់បទល្មើសដែរគឺៈ

- ទោសដែលប្រកាសចំពោះបទឧក្រិដ្ឋ មានអាជ្ញាយុកាល ២០ឆ្នាំ
- ទោសដែលប្រកាសចំពោះបទមជ្ឈិម មានអាជ្ញាយុកាល ៥ឆ្នាំ
- ទោសដែលប្រកាសចំពោះបទលហុ មានអាជ្ញាយុកាល ១ឆ្នាំ[86] ។

ចំណុចចាប់ផ្តើមនៃអាជ្ញាយុកាល គឺត្រូវចាប់ផ្តើមរាប់ពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសដែលចេញ ដោយតុលាការចូលជាស្ថាពរ ។

ឧទាហរណ៍ៈ បុគ្គលឈ្មោះ "ក" បានប្រព្រឹត្តអំពើឃាតកម្ម ដែលជាបទឧក្រិដ្ឋ ហើយត្រូវបានតុលាការ កាត់ទោសឱ្យជាប់ពន្ធនាគារ ក៏ប៉ុន្តែជាការកាត់ទោសដោយកំបាំងមុខ ដោយសារតែ "ក" បានរត់គេចខ្លួនបាត់ ហើយគេមិនអាចចាប់ "ក" យកមកដាក់ក្នុងពន្ធនាគារបាន ។ ២០ឆ្នាំ ក្រោយពីថ្ងៃប្រកាសសាលក្រមស្ថាពរ ទោសដែលដាក់លើ "ក" នេះ នឹងត្រូវផុតអាជ្ញាយុកាល ។ បើទោះបីជា "ក" វិលត្រឡប់មកវិញ ក៏គេមិនអាចចាប់ "ក" ដាក់ពន្ធនាគារបានដែរ។

### ១.៣ ការលើកលែងទោសជាទូទៅ

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែល តម្រូវឱ្យមានសម្លេងគាំទ្រអនុម័ត ២ ភាគ ៣ នៃសមាជិករដ្ឋសភាទាំងមូល[87] ។

ច្បាប់លើកលែងទោសជាទូទៅអាចអនុម័តបានដោយមានមូលហេតុជាច្រើនដូចជា កុំឱ្យមានទណ្ឌិត ក្នុងពន្ធនាគារច្រើនពេកក្នុងឱកាសហេតុការណ៍សំខាន់ណាមួយ ។ល។

#### ១.៣.១ អានុភាព

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅមានអានុភាពលុបចោល ដោយប្រតិសកម្មនូវការផ្តន្ទាទោស អំពើល្មើស ។ អំពើល្មើសដែលទទួលបាននូវការលើកលែងទោសត្រូវបានគេចាត់ថាមិនមែនជាបទល្មើស ឡើយ ។

ការលើកលែងទោសជាទូទៅមានអានុភាពដូចខាងក្រោម[88]ៈ

- ទោសមិនអាចយកមកអនុវត្តបានទេៈ មានន័យថា បណ្តឹងអាជ្ញាត្រូវរលត់ចំពោះអំពើល្មើសដែល ទទួលបាននូវការលើកលែងទោស ហើយមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយ ។
- ទោសកំពុងអនុវត្តត្រូវបានបញ្ចប់ៈ មានន័យថា ប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរ ការផ្តន្ទា ទោសនោះត្រូវទុកជាឥតបានការ ។

---

[86] មាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[87] មាត្រា ៩០ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

[88] មាត្រា ១៤៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

- ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ ជនជាប់ទោសមិនអាចទាមទារសំណងពីរដ្ឋវិញបានទេ ។

ការលើកលែងទោសជាទូទៅមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទាមទារសំណងការជួសជុលនៃការខូចខាតឡើយ[89] ។

**១.៣.២ ការបន្ធូរបន្ថយ និងការលើកលែងទោសនៅពិធីបុណ្យជាតិ**

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែកទោសចំពោះទណ្ឌិតត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ[90]៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ។

៣-ពិធីបុណ្យវិសាខបូជា ។

៤-ពិធីបុណ្យឯករាជ្យជាតិ ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬ ព្រឹត្តិការណ៍ធំៗរបស់ជាតិ ។ ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬ រួមគ្នា ។

**១.៣.៣ លក្ខខណ្ឌការបន្ធូរបន្ថយទោស និងការលើកលែងទោសទណ្ឌិត**

ការបន្ធូរបន្ថយទោស និងការលើកលែងទោសទណ្ឌិត គឺមានលក្ខខណ្ឌ ២ គឺលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌដោយឡែក ។ លក្ខខណ្ឌទូទៅ គឺពិចារណាពីស្ថានភាពនៃអត្តចរិក ភាពសកម្ម ការគោរពវិន័យកំឡុងពេលជាប់ពន្ធនាគារ និងហេតុផលមនុស្សធម៌ចំពោះជនដែលងាយរងគ្រោះជាដើម ។ លក្ខខណ្ឌដោយឡែក គឺជាលក្ខខណ្ឌដែលគិតពីរយៈពេលដែលទណ្ឌិតបានទទួលរងទោស រួមមាន ១ ភាគ ៣ ឬ ២ ភាគ ៣ នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ។

**១.៣.៣.១ លក្ខខណ្ឌទូទៅ**

ការបន្ធូរបន្ថយទោស និងការលើកលែងទោសមិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ ដែលទណ្ឌិតគឺត្រូវបំពេញទៅតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចទទួលបានការអនុគ្រោះទោស ឬ ជាការលើកលែងទោសបាន ។ ការបន្ធូរបន្ថយទោស និងការលើកលែងទោសអាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬ សាលដីកាស្ថាពរប៉ុណ្ណោះ[91] ។

[89] មាត្រា ១៥១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[90] មាត្រា ៣ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ ២០២១ ។

[91] មាត្រា ៤ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១ ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោសអាចអនុវត្តចំពោះទណ្ឌិត ដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម[92] ៖

- ភ្ញាក់រលឹក និងខិតខំកែប្រែគំនិតមាយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់នៅក្នុងសង្គមវិញ ។
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត ។
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម ។
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិត ដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើទៅគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ។

ការបន្ធូរបន្ថយ និងការលើកលែងទោសអាចអនុវត្តផងដែរ ក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬ មានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬ ពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច ។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិត ដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ[93] ។

**១.៣.៣.២ លក្ខខណ្ឌដោយឡែក**

ទណ្ឌិតដែលអាចទទួលបានការបន្ធូរបន្ថយទោស លុះត្រាតែ ទណ្ឌិតនោះបានបំពេញលក្ខខណ្ឌតាមមាត្រា៥ និងបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ។ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន[94] ។

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ដោយអាស្រ័យពីទោសដាក់ពន្ធនាគារ ចាប់ពី១ឆ្នាំ ដល់៣០ឆ្នាំ និងទោសដាក់ពន្ធនាគារអស់មួយជីវិត៖

- ទោសដាក់ពន្ធនាគារកំណត់ពី១ឆ្នាំ ដល់ក្រោម៥ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន៣ខែ ។
- ទោសដាក់ពន្ធនាគារកំណត់ពី៥ឆ្នាំ ដល់ក្រោម១០ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន៦ខែ ឬ ៣ខែ ។

[92] មាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១ ។

[93] មាត្រា ៦ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ ២០២១ ។

[94] មាត្រា ៧ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ ២០២១ ។

- ទោសដាក់ពន្ធនាគារកំណត់ពី១០ឆ្នាំ ដល់ក្រោម២០ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន៩ខែ ឬ ៦ខែ ឬ ៣ខែ ។
- ទោសដាក់ពន្ធនាគារកំណត់ពី២០ឆ្នាំ ដល់៣០ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន១២ខែ ឬ ៩ខែ ឬ ៦ខែ ឬ ៣ខែ ។
- ទោសដាក់ពន្ធនាគារមួយជីវិតអាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម៣០ឆ្នាំ ។

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានតែម្តងគត់ក្នុងរយៈពេល១២ខែ ។ ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសច្រើនដងបាន លុះត្រាតែ ទណ្ឌិតនោះបានទទួលរងទោសពាក់កណ្តាលនៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ តែការបន្ធូរបន្ថយនេះមិនអាចធ្វើឡើងច្រើនជាង១ដងបានទេ ក្នុងរយៈពេល១២ខែ ។

ចំពោះទណ្ឌិតដែលត្រូវបានកំណត់ទោសដាក់ពន្ធនាគារមួយជីវិត ក្រោយពីបានបន្ថយមកត្រឹម៣០ឆ្នាំ អាចនឹងបានទទួលការបន្ធូរបន្ថយច្រើនដងទៀតបាន ។ ប៉ុន្តែ ទោះជាទណ្ឌិតនោះបានទទួលការបន្ធូរបន្ថយទោសច្រើនដងក៏ដោយ ក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវឱ្យបានយ៉ាងតិច២០ឆ្នាំ ។

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចទទួលការលើកលែងទោស ក្នុងករណី ទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគារចំនួនពីរភាគបីនៃទោសរបស់ខ្លួន ។ ដោយឡែក ចំពោះទណ្ឌិតដែលទទួលទោសដាក់ពន្ធនាគារអស់មួយជីវិត អាចទទួលការលើកលែងទោស ប្រសិនបើ ទណ្ឌិតនោះបានអនុវត្តទោសយ៉ាងតិច៣០ឆ្នាំ ឬ ២០ឆ្នាំ ក្នុងករណីដែលមានការបន្ធូរបន្ថយទោស[95]។

## ១.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺសំដៅដល់គោលការណ៍នៃការច្រានចោល ឬ លុបចោលនូវបទប្បញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ ។ វាត្រូវបានយកមកអនុវត្តនៅពេលដែលច្បាប់ព្រហ្មទណ្ឌថ្មីនោះមានអានុភាពអនុវត្តចូលជាធរមាន ហើយបានបញ្ញត្តិអំពីលក្ខខណ្ឌនៃការអនុវត្ត និងវិធាននៃការនិរាករណ៍ ចំពោះបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន ។

ការអនុវត្តច្បាប់ដែលបានលុបចោលបទល្មើស គឺសំដៅទៅលើបទប្បញ្ញត្តិដែលលុបចោលបទល្មើសណាមួយនោះត្រូវតែអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនោះចូលជាធរមាន មិនអាចចោទប្រកាន់បានទៀតឡើយ ហើយប្រសិនបើ ការចោទប្រកាន់នោះកំពុងតែប្រព្រឹត្ត ក៏ត្រូវបានបញ្ចប់ដែរ[96] ។ ដូច្នេះ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺជាការច្រានចោលនូវបទប្បញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ ដែលផ្ទុយនឹងបទបញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌថ្មី នៅពេលដែលច្បាប់ថ្មីចូលជាធរមានដែលមានអានុភាពអនុវត្តនេះ គឺមានការពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាពសុទ្ធសាធ ព្រោះច្បាប់ដែលកំណត់អំពើមួយជាបទល្មើសលុះត្រាច្បាប់នោះនៅជាធរមានទើបមានអានុភាពអនុវត្ត ។ ដោយសារច្បាប់ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មី ដូចនេះជា

[95] មាត្រា ១០ នៃព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១ ។

[96] មាត្រា ៩ វាក្យខណ្ឌទី១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

គោលការណ៍ អំពើដែលច្បាប់មុនកំណត់ជាបទល្មើស តែត្រូវបានច្បាប់ថ្មីបដិសេធ អំពើនោះមិនអាចត្រូវបានចោទប្រកាន់ទៀតឡើយ ។

អានុភាពនៃបទប្បញ្ញត្តិ ដែលលុបចោលបទល្មើសនេះមិនត្រឹមតែហាមមិនអោយចោទប្រកាន់ទេ តែថែមទាំងកំណត់ថារាល់ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តក៏ត្រូវបានបញ្ចប់ ហើយបើមានការប្រកាសទោសរួចហើយ ការផ្តន្ទាទោសនេះមិនត្រូវអនុវត្តបានទេ ឬ ត្រូវតែបញ្ឈប់ការអនុវត្ត[97] ។

**១.៤.១ និរាករណ៍នៃច្បាប់ដោយតុណ្ហីភាព**

ចំពោះការនិរាករណ៍ប្រភេទនេះ គឺសំដៅដល់ច្បាប់ណាមួយដែលកំពុងត្រូវបានអនុវត្តរហូតមកដល់ថ្ងៃដែលច្បាប់ថ្មីមួយទៀតបានចូលខ្លួនជាធរមាន ហើយបានប្រកាសឱ្យប្រើដោយមិនបានប្រកាសបញ្ជាក់ច្បាស់លាស់ថា ច្បាប់ចាស់ត្រូវបានលុប ឬ ឈប់ប្រើដោយស្ងៀមស្ងាត់ស្រាប់តែច្បាប់ថ្មីបានបង្ហាញខ្លួនជំនួសតែម្តង ។

**១.៤.២ និរាករណ៍នៃច្បាប់ដោយមានការបង្ហាញខ្លួននៃច្បាប់ថ្មី**

ចំពោះការនិរាករណ៍នៃច្បាប់ប្រភេទនេះវិញ គឺតែងតែឃើញថាមានលក្ខណៈងាយស្រួលយល់ជាងការនិរាករណ៍នៃច្បាប់ដោយតុណ្ហីភាព ។ ព្រោះអង្គការនីតិប្បញ្ញត្តិមុននឹងប្រកាសឱ្យប្រើច្បាប់ថ្មី គឺត្រូវបានធ្វើការផ្សព្វផ្សាយក្នុងរយៈពេលតែមួយឱ្យមហាជនបានដឹងបានស្គាល់ និងមានច្បាប់ថ្មីមកជំនួសច្បាប់ដែលអនុវត្តច្បាប់អន្តរកាលវិញ[98] ។

## **១.៥ អាជ្ញាអស់ជំនុំ**

អនុលោមតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជា ក្រោយការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ[99] ។

គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬ យកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬ បានលើកលែងទោសស្រមតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ[100] ។

ប្រសិនបើក្នុងរឿងព្រហ្មទណ្ឌ តុលាការបានសម្រេចសេចក្តីដាក់ទោសជនជាប់ចោទនោះ បានសេចក្តីថាជនជាប់ចោទមានកំហុស ហេតុដូចនេះបណ្តឹងរដ្ឋប្បវេណី និងទទួលបានជោគជ័យដោយស្វ័យប្រវត្តិ ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ជនរងគ្រោះក៏ពុំអាចនឹងទទួលបាននូវសំណងពីការខូចខាតពីជនជាប់ចោទដែរ ។ ប៉ុន្តែករណីខ្លះ ទោះបីជាតុលាការឱ្យជនជាប់ចោទរួចផុតពីបទចោទក៏ដោយ ក៏ជនរងគ្រោះនៅតែទទួលបានសំណងដែរ ។ ព្រោះថាអំពើរបស់ជនជាប់ចោទពុំមែនជាបទល្មើស តែជាអំពើល្មើសផ្នែករដ្ឋប្បវេណី ។

គោលការណ៍មិនអាចជំនុំជម្រះពីរដងក្នុងរឿងតែមួយនាំឱ្យមានផលវិបាក និងមានកំណត់តាមក្រម

[97] មាត្រា ១០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[98] មាត្រា ៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

[99] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[100] មាត្រា ១៤ ចំណុច៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយបានកំណត់ថាបណ្ដឹងអាជ្ញាពុំអាចធ្វើបានទៀតទេ ប្រសិនបើមានសាលក្រមតុលាការសម្រេចដោះលែងជនជាប់ចោទចំពោះអំពើដដែលនេះ ទោះបីជា ក្រោយពេលមានសាលក្រមស្ថាពរហើយ គេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ[101] ។

## ផ្នែកទី២៖ មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្ដឹងអាជ្ញា

មូលហេតុដែលមានកំណត់ក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាមូលហេតុទូទៅ ហើយប្រសិនបើមានស្ថានភាពណាមួយកើតឡើងដូចដែលមានកំណត់ក្នុងមាត្រានេះនោះបណ្ដឹងអាជ្ញានឹងរលត់ ។ ប៉ុន្តែចំពោះមូលហេតុផ្សេងទៀត ដែលបណ្ដឹងអាជ្ញានឹងរលត់ទៅបាន លុះត្រាតែ មានច្បាប់ពិសេសផ្សេងទៀតចែងយ៉ាងជាក់ទើបបណ្ដឹងអាជ្ញានោះរលត់[102] ។ ករណីនេះមានស្ថានភាព ៣ យ៉ាងគឺការសម្របសម្រួលដោយរដ្ឋ ការដកពាក្យបណ្ដឹង និងការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល ។

### ២.១. ការសម្របសម្រួលដោយរដ្ឋ

ជាគោលការណ៍ ការសម្រុះសម្រួលមិនអាចធ្វើទៅបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ ។ ប៉ុន្តែករណីមានច្បាប់ពិសេសចែងកំណត់ពីការសម្របសម្រួលរបស់រដ្ឋ គឺអាចអនុញ្ញាតឱ្យរលត់បណ្ដឹងអាជ្ញាបាន ។

ការអនុវត្តការព្រមព្រៀងនេះធ្វើឱ្យរលត់បណ្ដឹងអាជ្ញាតាមការសម្របសម្រួលនេះជាអាទិ៍ ៖

- ការទទួលស្គាល់កំហុសរបស់ជនល្មើស
- ការសន្យាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀត
- ការធានាចូលទៅរួមក្នុងសង្គមវិញ
- ការសុំពេលដើម្បីជួសជុលការខូចខាតចំពោះជនរងគ្រោះ
- ការទទួលការព្រមានរបស់ព្រះរាជអាជ្ញា
- និងការសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដទៃទៀត ករណីចែងដោយច្បាប់ដោយឡែក ។

### ២.២ ការដកពាក្យប្តឹង

ជាទូទៅ ការដកពាក្យប្តឹងដោយជនរងគ្រោះពុំអាចធ្វើឱ្យអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញារលត់ទេ ។ ប៉ុន្តែចំពោះបទល្មើសមួយចំនួន ការដកពាក្យប្តឹងរបស់អ្នកទទួលរងការខូចខាតនាំឱ្យរលត់បណ្ដឹងអាជ្ញាដែរ ដោយការដកពាក្យប្តឹងនៅក្នុងករណី ដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ[103] ។

ជាក់ស្តែង ក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ បានចែងថា "ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើរពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ ។ ករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនេះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជា មានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ"[104] ។ តាមន័យនេះ អំពើហិង្សាទាំងឡាយ

---

[101] មាត្រា ១៤ ចំណុចទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[102] មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[103] មាត្រា ៨ ចំណុចទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[104] មាត្រា ៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ។

ក្នុងគ្រួសារ ដែលចូលជាបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទមជ្ឈិមស្រាល ឬ បទលហុ ជនរងគ្រោះជានីតិជនអាចធ្វើសំណើរដើម្បីកុំឱ្យមានការចោទប្រកាន់ នោះព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់បានឡើយ ។ សំណើរនេះត្រូវចាត់ទុកជាការដកពាក្យបណ្ដឹង បើសិនមានការចោទប្រកាន់រួច ដែលនាំឱ្យបណ្ដឹងអាជ្ញាត្រូវផុតរលត់ ។

មួយវិញទៀត ច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ២០០៦ បានចែងថា "ក្នុងករណីដែលមានចែងក្នុងមាត្រា ៧ ខាងលើ ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្ដឹងអាជ្ញាបាន ប្រសិនបើ មានបណ្ដឹងរបស់សហព័ទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់"[105] ។ នេះមានន័យថា ករណីសហព័ទ្ធណាម្នាក់បានប្រព្រឹត្តបទផិត ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ២០០៦ បណ្ដឹងអាជ្ញានឹងរលត់ ប្រសិនបើមានការស្នើសុំពីសហព័ទ្ធដែលជាជនរងគ្រោះ ។

## ២.៣ ការបង់ប្រាក់ពិន័យសរុបដើម្បីសម្របសម្រួលជាមួយរដ្ឋ

បទល្មើសមួយចំនួនគឺអាចបញ្ចប់ដោយមិនមានបណ្ដឹងអាជ្ញា ដោយគ្រាន់តែបង់ប្រាក់ពិន័យជាប្រាក់ប៉ុណ្ណោះ ។

ជាក់ស្ដែង ក្នុងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ បានចែងថា "បទល្មើសចរាចរណ៍ដែលត្រូវផ្ដន្ទាទោសពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកអាចសម្រុះសម្រួល ក្នុងករណីមានគ្រោះថ្នាក់ដែលបណ្ដាលឱ្យសងតែសំណងខូចខាត"[106] ។ នេះមានន័យថា ចំពោះបទល្មើសដែលត្រឹមផ្ដន្ទាទោសត្រឹមពិន័យជាប្រាក់ អាចឱ្យអ្នកប្រព្រឹត្តរួចផុតពីបណ្ដឹងអាជ្ញាតាមរយៈការបង់ប្រាក់ពិន័យអន្តរកាណ៍នេះតែម្ដង[107] ។

---

[105] មាត្រា ៨ នៃច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ២០០៦ ។

[106] មាត្រា ៦៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ ។

[107] មាត្រា ៨ ត្រង់ចំណុចទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទសារណាស្តីពី **"បណ្តឹងអាជ្ញា"** រួចមក យើងពិនិត្យឃើញថាសារណានេះ គឺមានលក្ខណៈសំខាន់ចំនួន៤ ដូចជាសញ្ញាណទូទៅ ការចាប់ផ្តើមនៃបណ្តឹង ចំណាត់ការ និងមូលហេតុនៃការរលត់ ។

បណ្តឹងអាជ្ញាមានគោលបំណង គឺដើម្បីការពារទៅដល់សណ្តាប់ធ្នាប់សាធារណៈនៅក្នុងសង្គមជាតិទាំងមូល តាមរយៈការពិនិត្យមើលពីអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់ ។ បណ្តឹងនេះមានលក្ខណៈដាច់ខាត ប្រសិនបើបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺនឹងមិនមានការលើកលែងឡើយ លើកលែងតែ មានករណីណាមួយដែលច្បាប់បានកំណត់ពីមូលហេតុនៃការរលត់បណ្តឹងនោះ ។ ការធ្វើបែបនេះគឺដើម្បីធានាឱ្យបានពីសន្តិសុខដល់សង្គមជាតិទាំងមូល ក្នុងការកំណត់ពីទណ្ឌកម្មយ៉ាងម៉ឺងម៉ាត់ទៅដល់ជនល្មើស ដែលជាគោលការណ៍ធ្វើឱ្យជនទាំងនោះមានភាពរាងចាល និងស្តារនីតិសម្បទាដើម្បីក្លាយជាបុគ្គលល្អក្នុងសង្គមវិញ ។

ការចាប់ផ្តើមនៃបណ្តឹងអាជ្ញា គឺជាដំណាក់កាលដំបូងដែលត្រូវចាប់ផ្តើម មុននឹងឈានដល់ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដែលនេះជាតួនាទីរបស់អយ្យការដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ស្ថាប័នអយ្យការគឺជាស្ថាប័នតែមួយគត់ ដែលមានសិទ្ធិក្នុងការចោទប្រកាន់ទៅជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្នុងនាមជាផលប្រយោជន៍ទូទៅ ។ បន្ថែមពីនេះទៅទៀត ជនរងគ្រោះ ឬ អ្នកតំណាងជនរងគ្រោះក៏អាចដាក់ពាក្យបណ្តឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ឬ ចំពោះមុខចៅក្រមស៊ើបសួរបាន ។ ពាក្យប្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ គឺទាមទារឱ្យមានការសរសេរទៅតាមទម្រង់មួយច្បាស់លាស់ទៅតាមច្បាប់កំណត់ ។ ដោយសារតែការធ្វើបែបនេះគឺមានភាពលំបាកទៅដល់ជនរងគ្រោះទើបមានការផ្តល់អត្ថិភាពដល់ពួកគាត់ក្នុងការស្នើសុំឱ្យសមត្ថកិច្ច ឬ ក៏អាចពឹងពាក់មេធាវីឱ្យជួយរៀបចំបាន ។

ចំណាត់ការនៃបណ្តឹងអាជ្ញាមុននឹងឈានដល់ការជំនុំជម្រះមានភាគីពីរសំខាន់ គឺមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ ។ មន្ត្រីនគរបាលយុត្តិធម៌គឺត្រូវធ្វើការស៊ើបអង្កេត និងធ្វើការកត់កំណត់ហេតុឱ្យបានល្អិតល្អន់ដើម្បីបញ្ជូនទៅព្រះរាជអាជ្ញា ។ មុនពេលធ្វើសេចក្តីសម្រេចថា ត្រូវតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើកាលានុវត្តភាពនៃការចោទប្រកាន់ តំណាងអយ្យការត្រូវដឹង និងថ្លឹងថ្លែងឱ្យបានម៉តចត់បំផុត ។ ការសម្រេចចិត្តប្តឹងចោទប្រកាន់របស់តំណាងអយ្យការ មានអានុភាពដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យអំពីបទល្មើសចំពោះបុគ្គលណាម្នាក់ ឬ ច្រើននាក់ ។

ការរលត់នៃបណ្តឹងអាជ្ញាគឺអាចធ្វើបានមុនពេលមានបណ្តឹងអាជ្ញា ឬ ក៏អំឡុងពេលដែលបណ្តឹងអាជ្ញាកំពុងត្រូវអនុវត្តនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ។ កាលណាបណ្តឹងអាជ្ញារលត់ ការចោទប្រកាន់លើបណ្តឹងអាជ្ញាគឺមិនអាចចាប់ផ្តើមបានទេ ហើយប្រសិនបើ បណ្តឹងអាជ្ញាកំពុងស្ថិតក្នុងនីតិវិធី គឺត្រូវបញ្ឈប់ភ្លាម។ ការធ្វើបែបនេះ មិនមែនមានន័យថាជាការបន្ធូរបន្ថយចំពោះជនល្មើសនោះទេ តែវាជាការផ្តល់ប្រយោជន៍ដល់ភាគីដែលជាជនល្មើសអាចមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីកែប្រែខ្លួនចូលក្នុងសង្គមវិញ ជាពិសេសអនីតិជន និងជនដែល

កំពុងជាប់កាតព្វកិច្ច ដូចជាចិញ្ចឹមបីបាច់គ្រួសារ ជាអាទិ៍ ។ មួយវិញទៀត ការធ្វើបែបនេះក៏ជួយសម្រួលទៅដល់ភាពរាំងស្ទះនៃសំណុំរឿងក្នុងតុលាការ និងផ្ដល់ប្រសិទ្ធិភាពក្នុងការអនុវត្តនីតិវិធីក្នុងតុលាការ ព្រោះនៅពេលសំណុំរឿងត្រូវបានកាត់បន្ថយ ចៅក្រមស៊ើបសួរ និងជំនុំជម្រះមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ ឯចំណុចពិសេសមួយទៀត គឺការកាត់បន្ថយទៅលើថវិការ និងពេលវេលាដោយបន្ថយការចំណាយទៅលើទណ្ឌិត និងកាត់បន្ថយចំនួនទណ្ឌិត ។

សរុបសេចក្ដីមក សារណាមួយនេះគឺបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីលក្ខណៈពិសេសរបស់បណ្ដឹងអាជ្ញា ក៏ដូចជានីតិវិធីផ្សេងៗដែលស្ថាប័នមានសមត្ថកិច្ចបានអនុវត្ត ក្នុងការធានាឱ្យបានពីសណ្ដាប់ធ្នាប់សាធារណៈ តាមរយៈការធានាឱ្យបាននៅប្រព័ន្ធយុត្តិធម៌ក្នុងវិស័យតុលាការ ។ គ្រប់ស្ថាប័នដែលមានសមត្ថកិច្ចក្នុងបណ្ដឹងអាជ្ញាទាំងអស់សុទ្ធតែមានតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួនទៅតាមច្បាប់កំណត់ ប្រសិនបើ មានចំណុចខ្វះចន្លោះនៃភាគីណាមួយ ប្រាកដណាស់ថានឹងប៉ះពាល់ទៅដល់ការរកយុត្តិធម៌ទៅដល់ជនរងគ្រោះ ។

# អនុសាសន៍

បើយើកក្រឡេកមើលសង្គមបច្ចុប្បន្ន យើងឃើញថាការអនុវត្តនីតិវិធីឱ្យស្របតាមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ នៅមានភាពខ្វះចន្លោះខ្លះៗនៅឡើយ ។ ជាក់ស្តែង នៅពេលដែលកសាងសំណុំរឿង មន្ត្រីនគរបាលខ្លះមិនបានស៊ើបអង្កេតឱ្យបានដិតដល់ ដែលធ្វើឱ្យសំណុំរឿងមានព័ត៌មានមិនគ្រប់គ្រាន់ ឬ អាចខុសពីការពិតទាំងស្រុងនៅពេលដែលបញ្ជូនទៅព្រះរាជអាជ្ញា ។ វាជាមូលហេតុដែលធ្វើឱ្យការសម្រេចការចោទប្រកាន់របស់ព្រះរាជអាជ្ញាធ្វើឡើងដោយភាពមិនត្រឹមត្រូវ ឬ ប្រាសចាកពីគោលការណ៍ដែលច្បាប់បានកំណត់ ។ ម្យ៉ាងទៀត ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញាដែលការពារផលប្រយោជន៍ទូទៅដល់សង្គម ព្រះរាជអាជ្ញាត្រូវតែគោរពជាដាច់ខាតតាមបទប្បញ្ញត្តិទាំងឡាយ ដែលកំណត់អំពីការធ្វើចំណាត់ការទៅលើសំណុំរឿង ដើម្បីរៀបចំជាបណ្តឹង និងមានភាពត្រឹមត្រូវ ប៉ុន្តែ ព្រះរាជអាជ្ញាខ្លះនូវតែមានភាពមិនច្បាស់លាស់ចំពោះការអនុវត្តនីតិវិធីដោយពិចារណាមិនបានគ្រប់ជ្រុងជ្រោយ ឬ ប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈ ដែលធ្វើឱ្យខ្លួនចោទប្រកាន់ខុសពីការពិត ឬ អនុវត្តខុសពីនីតិវិធីដែលបានកំណត់ ។ ម្យ៉ាងវិញទៀត យើងសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនដែលជាបុគ្គលពាក់ព័ន្ធនឹងដំណើរការនៃបណ្តឹងមិនបានយល់ដឹងពីច្បាប់ និងនីតិវិធី ដែលជាហេតុបណ្តាលឱ្យពួកគាត់ប្រព្រឹត្តទង្វើផ្សេងៗដែលនាំឱ្យរំខានដល់ដំណើរការដោះស្រាយ និងធ្វើឱ្យនីតិវិធីមានភាពយឺតយ៉ាវ ។ នៅពេលមានបទល្មើសកើតឡើង ការដាក់អោយបណ្តឹងអាជ្ញាមានចលនាដោយប្រជាពលរដ្ឋនៅមានចន្លោះខ្វះខាត ដែលពេលខ្លះគេឃើញថានៅពេលមាន បទល្មើសព្រហ្មទណ្ឌ គឺប្រជាពលរដ្ឋដែលជាជនរងគ្រោះបានធ្វើការសម្របសម្រួលគ្នាជាមួយបុគ្គលល្មើសនោះតាមរយៈការអនុវត្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ។ ការអនុវត្តបែបនេះពិតជាស្តែងអោយឃើញថាផ្ទុយពីអ្វីដែលច្បាប់បានចែងទាំងស្រុង ដែលជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌគឺជាជនដែលបង្កអសន្តិសុខដល់សង្គម ត្រូវតែច្បាប់ជាអ្នកចាត់វិធានការផ្តន្ទាទោសអោយសាកសមទៅនឹងអំពើដែលជនល្មើសបានប្រព្រឹត្តក្នុងគោលបំណងរក្សាសណ្តាប់ធ្នាប់ ការពារប្រយោជន៍សាធារណៈនៅប្រទេសកម្ពុជាយើង ដែលការផ្តន្ទាទោសមិនត្រឹមតែផ្តន្ទាទោសជាសំណងរដ្ឋប្បវេណីនោះទេ ។

ដូច្នេះដើម្បីធានាទៅដល់ការរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខសង្គមឱ្យបានពិតប្រាកដមែន គឺត្រូវផ្តើមពីការពង្រឹងទៅលើការអនុវត្តច្បាប់ និងការធានាឱ្យបានថាប្រជាពលរដ្ឋមានការយល់ដឹងពីច្បាប់ ដែលធ្វើឱ្យពួកគាត់អាចការពារសិទ្ធិរបស់ខ្លួននៅពេលមានការរំលោភបំពាន ។ ដើម្បីឱ្យការអនុវត្តច្បាប់នៅក្នុងប្រព័ន្ធយុត្តាធិការនៃប្រទេសកម្ពុជាប្រព្រឹត្តទៅបានរលូន និងប្រកបដោយភាពយុត្តិធម៌ រាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំនៅក្នុងស្ថាប័នតុលាការទាំងអស់ គប្បីចាត់វិធានការយ៉ាងម៉ឺងម៉ាត់ទៅលើមន្ត្រីអសកម្មទាំងឡាយឱ្យខិតខំពង្រឹងខ្លួនឯង គោរពទៅតាមគោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយ ព្រមទាំងប្រកាន់យកភាពត្រឹមត្រូវ និងយុត្តិធម៌ដើម្បីបម្រើដល់ប្រយោជន៍ជូនប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល ។ បន្ថែមពីនេះទៀត រាជរដ្ឋាភិបាលត្រូវតែធ្វើការផ្សព្វផ្សាយពីចំណេះដឹងផ្នែកច្បាប់ទៅដល់ប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយដោយផ្ទាល់ដូចជាការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬ កម្មវិធីផ្សេងៗដែលប្រជាពលរដ្ឋអាចចូលរួមដោយផ្ទាល់ ។

មួយវិញទៀត គឺការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា ទូរទស្សន៍ វិទ្យុ ខ្សែភាពយន្តអប់រំ និងប្រព័ន្ធបណ្តាញសង្គមជាដើម ។ ក្រៅពីនេះទៀត រាជរដ្ឋាភិបាលក៏គួរតែលើកទឹកចិត្តទៅដល់អង្គការសង្គមស៊ីវិល សមាគម ឬ ប្រជាពលរដ្ឋនានា ដែលមានបំណងក្នុងការផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ទៅដល់ប្រជាពលរដ្ឋ ដោយធ្វើការសហការណ៍ និងផ្តល់សិទ្ធិសេរីភាពពេញលេញដល់ពួកគាត់ក្នុងការធ្វើសកម្មភាពផ្សព្វផ្សាយផ្សេងៗដូចដែលអ្វីដែលមានចែងក្នុងច្បាប់ពីសិទ្ធិទទួលបានការអប់រំ ។

# គន្ថនិទ្ទេស

## I. លិខិតបទដ្ឋានគតិយុត្ត


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

២. ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១ ។

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

៤. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ។

៥. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

៦. ច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ ។

៧. ច្បាប់ភូមិបាល ឆ្នាំ២០០១ ។

៨. ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ។

៩. ច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦ ។

១០. ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ។

១១. ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គតុលាការ ឆ្នាំ២០១៤ ។

១២. ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ ។

១៣. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ឆ្នាំ១៩៧៦ ។


## II. សៀវភៅមេរៀន


១. សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម កើត រិទ្ធ ឆ្នាំ២០១៦ ។

២. សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល ។

៣. សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពុណ្ណារិទ្ធិ និង លោកស្រីសាស្ត្រាចារ្យ ចាំ ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ។

៤. មេរៀន នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ៖ ឯកឧត្តម ហ៊ី សោភា ។

៥. មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចងក្រងដោយ ឯកឧត្តម សឿង មុន្នីរ័ត្ន បកស្រាយដោយ ឯកឧត្តម ហ៊ី សោភា ឯកឧត្តម ប៊ុន ហ៊ុន ឯកឧត្តម កើត រិទ្ធ ឯកឧត្តម ផូវ សំភី និងលោកជំទាវចាំង ស៊ីណាត ។

៦. សៀវភៅ នីតិរដ្ឋប្បវេណី រៀងរៀងដោយ សាស្ត្រាចារ្យ ហាប់ ផល្លី ឆ្នាំ ២០០១ ។

៧. សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និង លោក ខាន់ សុខា ។


## III. ឯកសារផ្សេងៗ


១. សេចក្តីថ្លែងការណ៍របស់ ឯកឧត្តម ជិន ម៉ាលីស ដែលផ្សាយដោយសារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២០ ។

២. ឯកសារមេរៀន នីតិវិធីព្រហ្មទណ្ឌកម្ពុជា រៀបរៀងដោយ ចក សម្បត្តិ អនុប្រធានសមាគមត្រាជូ ។

៣. ឯកសារស្លាយមេរៀនស្តីពី ការតម្កល់រឿងទុកឥតចាត់ការ រៀបរៀងដោយ ន.ស.រ ឆ្នាំ២០១៧ ។

# បញ្ជីឧបសម្ព័ន្ធ

១. ពាក្យបណ្ដឹង
២. ពាក្យបណ្ដឹងទាស់
៣. ពាក្យបណ្ដឹងតវ៉ា
៤. ពាក្យសុំពឹងពាក់មេធាវី
៥. ពាក្យប្ដឹងសុំឱ្យធ្វើការចោទប្រកាន់
៦. ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
៧. ដីកាបញ្ជាឱ្យឃុំខ្លួន
៨. ដីកាបង្គាប់អោយចាប់ខ្លួន
៩. ដីកាតម្កល់រឿងទុកឥតចាត់ការ
១០. ដីកាបញ្ជាឱ្យចូលខ្លួន
១១. ដីកាបញ្ជូនសំណុំរឿងមូលឱ្យពិនិត្យ
១២. សេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ
១៣. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្ដឹង

**ដើមចោទ:** ខ្ញុំបាទឈ្មោះ.............................................................មានអាសយដ្ឋានបច្ចុប្បន្ន.............................................................
តំណាងដោយលោក ........................តួនាទីជា ............................ ទូរស័ព្ទទំនាក់ទំនង ..................................................។

**ចុងចម្លើយ:** ឈ្មោះ .................... ភេទ..............ថ្ងៃខែឆ្នាំកំណើត .............. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ................ ចុះថ្ងៃទី ............... និង.................... ថ្ងៃខែឆ្នាំកំណើត ..................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............. ចុះថ្ងៃទី .......... មានទីលំនៅបច្ចុប្បន្ននៅភូមិ..........ឃុំ/សង្កាត់......... ស្រុក/ខណ្ឌ.................. ខេត្ត/ក្រុង ..........................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**................

**កម្មវត្ថុ:** ប្ដឹងសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម:

១. ..........................................................
២. ..........................................................

**យោង៖** - ..........................................................
- ........................................................

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបអំពីដំណើររឿងដូចតទៅ៖ .................................. មានទីលំនៅបច្ចុប្បន្ននៅភូមិ...............ឃុំ/សង្កាត់.......... ស្រុក/ខណ្ឌ.......................... ខេត្ត/ក្រុង ..........................................................................................................................................................................................................
..........................................................................................................................................................................................................

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចមានក្នុងកម្មវត្ថុខាង លើដោយក្ដីក្ដីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅ..........................ថ្ងៃទី.............. ខែ............ ឆ្នាំ២០......

ស្នាមមេដៃស្ដាំ

**ឈ្មោះ**

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌
ផ្នែកពាក្យបណ្ដឹង
ចូល លេខ 164 ម៉ោង 10:00
មកដល់ ថ្ងៃទី 27/5/2019

អគ្គលេខាធិការដ្ឋានសាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ 3150
ថ្ងៃទី 24 ខែ 05 ឆ្នាំ 2019
ម៉ោង 15:45 នាទី

**<u>ពាក្យបណ្ដឹង</u>**

ខ្ញុំបាទឈ្មោះ ឆ្នាំកំណើត១៩៧២ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវលេខ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**<u>សូមគោរពជូន</u>**

**លោកព្រះរាជអាជ្ញា អមសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u> ៖** ប្ដឹងឈ្មោះ ភេទប្រុស មុខរបរ

ពីបទល្មើសព្រហ្មទណ្ឌដូចជា៖

១/- បង្កើតសំណុំរឿងអនុវត្តលេខ ១៤៣ ចុះថ្ងៃទី២០.០៥.២០០៥ ក្លែងក្លាយ រៀបចំគម្រោងការទុច្ចរិត ដើម្បីធ្វើស៊ី ឬ ចង់បានផ្ទះ(ផ្ទះលេខ៦២E₀ E₁ E₂ ផ្លូវលេខ៥៩៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ) របស់ខ្ញុំបាទ ។

២/- អន្តរាគមន៍ដោយខុសច្បាប់ ទៅលើមន្ត្រីសាធារណៈ តាមរយៈការចេញលិខិតរបស់អាជ្ញាសាលា (ស៊ិន សៀងហេង) លេខ ០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ។

៣/- បទរំលោភបំពានច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា , ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

សូមទាមទារសំណង ជំងឺចិត្តព្រមទាំងសេវាកម្មផ្នែកច្បាប់ចំនួន USD១០០០០០០ (មួយលានដុល្លារអាមេរិក) ។

**<u>យោង</u> ៖** - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតរបស់អាជ្ញាសាលា (ស៊ិន សៀងហេង) លេខ០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ សូមជម្រាបជូន **លោកព្រះរាជអាជ្ញា** មេត្តាជ្រាបថា: នៅថ្ងៃទី២៦.០៤.២០១៩ អាជ្ញាសាលាឈ្មោះ ស៊ិន សៀងហេង បានចេញលិខិតរបស់ខ្លួន

០៧ ចុះថ្ងៃទី២៦.០៤.២០១៩ ជម្រាបមកលោកអភិបាល នៃគណៈអភិបាលខណ្ឌទួលគោក ដើម្បីបំពេញការងារ តាមគម្រោងការ ជំទុច្ចរិតរបស់គាត់ ដែលមានចេតនា ចង់ធ្វើស៊ី ឬ បន្លំ ឬ ចង់បាន ដោយរំលោភបំពានច្បាប់ មករឹបអូសផ្ទះ(ផ្ទះលេខ៦២$E_0$ $E_1$ $E_2$ផ្លូវលេខ៥៥៨ ភូមិ៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ) របស់ខ្ញុំបាទ ដូចមានរៀបរាប់ក្នុងលិខិតរបស់លោក ។ ចេតនាជំទុច្ចរិតនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដូចមានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរបំផុត ហើយធ្វើឱ្យជះឥទ្ធិពលជំរាបក្រក់ដល់សាលាដំបូងរាជធានីភ្នំពេញថែមទៀតផង ។ ហេតុនេះ សូម **លោកព្រះរាជអាជ្ញា** មេត្តាសម្រេច ចោទប្រកាន់ លើឈ្មោះ

បញ្ជូនទៅតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ និងសងសំណងជំងឺចិត្ត ព្រមទាំងសេវាកម្មផ្លូវច្បាប់ ជូនខ្ញុំបាទ ចំនួន USD១000000(មួយលានដុល្លារអាមេរិក) ហើយចំពោះសំណងដែលខ្ញុំបាទទទួលបាននោះ ខ្ញុំបាទនឹងប្រគល់ជូនកាកបាទក្រហមកម្ពុជា ចំនួន ៥០%(ហាសិបភាគរយ) និងមន្ទីរពេទ្យគន្ធបុប្ផា ចំនួន៥០%(ហាសិបភាគរយ) ដើម្បីរួមចំណែកជួយប្រទេសជាតិ ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

សូម **លោកព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

**ស្នាមមេដៃស្តាំ**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ក្រសួងយុត្តិធម៌
- ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- អង្គភាពប្រឆាំងអំពើពុករលួយ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី២

ការិយាល័យមេធាវី…………..
លេខ:…………………………

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបមន្តទី ២១

**<u>ពាក្យបណ្តឹងទាស់</u>**

ខ្ញុំមេធាវី…………………អត្តលេខ:…………សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ…………………………..ត្រូវជា……………………ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ………………ចុះថ្ងៃទី……ខែ………ឆ្នាំ………របស់សាលាដំបូង…………………………។

**<u>សូមគោរពជូន</u>**

………………………………………………………………………………….

**<u>កម្មវត្ថុ:</u>**ប្តឹងទាស់នឹងសាលក្រម/សាលដីកាលេខ………… ចុះថ្ងៃទី………ខែ…………ឆ្នាំ………..
របស់………………………………………………………………។

**<u>យោង:</u>** - មាត្រា ៣៦៥, ៣៦៦,៣៦៧, ៣៦៨, ៣៦៩, ៣៧០ និងមាត្រា៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧

- សាលក្រម/ សាលដីកាកំបាំងមុខលេខ………… ចុះថ្ងៃទី……… ខែ…… ឆ្នាំ…………
- លិខិតជូនដំណឹងស្តីពីសាលក្រម/សាលដីកាកំបាំងមុខលេខ……ចុះថ្ងៃទី……ខែ......ឆ្នាំ……
- លិខិតប្រគល់សិទ្ធិប្តឹងទាស់ចុះថ្ងៃទី……… ខែ………… ឆ្នាំ…………

សេចក្តីដូចបានជម្រាបជូនតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន…………………… មេត្តាជ្រាបនះដោយកូនក្តីខ្ញុំឈ្មោះ……………………មិនសុខចិត្តនឹងសាលក្រម/សាលដីកាកំបាំងមុខ ខាងលើត្រង់ចំណុច………………………… ………………………………………………………………… នៃសាលក្រម/ សាលដីកាកំបាំងមុខ។

អាស្រ័យហេតុនេះសូម……………………………………………………………… មេត្តាទទួល និងចាត់ការលើបណ្តឹងទាស់តាមនីតិវិធីនៃច្បាប់ដោយក្តីអនុគ្រោះ។

ធ្វើនៅ…………………… ថ្ងៃទី………ខែ………… ឆ្នាំ………………

ហត្ថលេខា និងត្រា


អាសយដ្ឋានផ្ទះលេខ……… ផ្លូវលេខ……… ភូមិ………………… ឃុំ/សង្កាត់…………………… ស្រុក/ខណ្ឌ…………..ខេត្ត/រាជធានី……
ទូរស័ព្ទ:……………………………………ទូរសារ:…………………………………អ៊ីម៉ែល:……………………………………………

ឧបសម្ព័ន្ធទី៣

អ.ជ.
សាលាដំបូងខេត្តកណ្ដាល
លេខ 1196
ថ្ងៃទី 27-05-2021
ម៉ោង 14:10

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹងតវ៉ា**

នាងខ្ញុំឈ្មោះ ជាតិខ្មែរ អាយុ៣៥ ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពជូន**
**ឯកឧត្ដមព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ ៖** ប្ដឹងតវ៉ានឹងដីកាសម្រេចលេខ ៣១៧ ដកមចក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

**យោង ៖** មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
លិខិតជូនដំណឹងលេខ ៣៣២ លជណ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរព និងជម្រាបជូន **ឯកឧត្ដមព្រះរាជអាជ្ញា** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ អយ្យការអមសាលាដំបូងខេត្តកណ្ដាល បានចេញដីកាសម្រេចលេខ ៣១៧ ដកមចក ដោយបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើពាក្យបណ្ដឹងរបស់នាងខ្ញុំ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ដែលការសម្រេចតម្កល់រឿងទុកឥតចាត់ការខាងលើនេះ គឺផ្ដល់ភាពអយុត្តិធម៌ណាស់សម្រាប់នាងខ្ញុំ ដែលជាជនរងគ្រោះ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្ដមព្រះរាជអាជ្ញា** មេត្តាទទួលពាក្យបណ្ដឹងតវ៉ា និងចាត់ការតាមនីតិវិធីច្បាប់ដោយអនុគ្រោះ ។

សូម **ឯកឧត្ដមព្រះរាជអាជ្ញា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ខេត្ត កណ្ដាល ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១
ស្នាមមេដៃស្ដាំ

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំពឹងពាក់មេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ…………………………………អាយុ……………ឆ្នាំ សញ្ជាតិ……………………… មុខរបរ…………………………………………ទីលំនៅបច្ចុប្បន្នផ្ទះលេខ…………ផ្លូវ……………ក្រុម…………… ភូមិ………………………………ឃុំ/សង្កាត់……………………………ស្រុក/ខណ្ឌ…………………………………… ខេត្ត/រាជធានី………………………… ត្រូវជា…………………………………………………។

## សុំពឹងពាក់

លោក/លោកស្រីមេធាវី………………………អត្តលេខ…………ការិយាល័យ………………………… ……………………………………អាសយដ្ឋានផ្ទះលេខ………………ផ្លូវលេខ………… ភូមិ……………………… ឃុំ/សង្កាត់……………………………… ស្រុក/ខណ្ឌ………………………… ខេត្ត/រាជធានី……………………… ដើម្បីការពារសិទ្ធិអោយខ្ញុំបាទ/នាងខ្ញុំនៅចំពោះមុខ……………………………………………………………… ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ……………ចុះថ្ងៃទី………ខែ…………ឆ្នាំ………របស់……………………… … … …………………………… ក្នុងនាមជា: ……………………………………។

ចាប់ពីថ្ងៃខ្ញុំបាទ/នាងខ្ញុំចុះហត្ថលេខា រឺផ្តិតម្រាមដៃនេះតទៅ គឺមេធាវីខាងលើមានសិទ្ធិការពារផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ………………………ថ្ងៃទី………ខែ…………… ឆ្នាំ…………

**ស្នាមម្រាមដៃសាមីខ្លួន**

បានឃើញ និង យល់ព្រម

ធ្វើនៅ…………………ថ្ងៃទី……… ខែ……………ឆ្នាំ……………

**ហត្ថលេខា និង ត្រា**

ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ១១២៦
ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៦
លេខ៖......៥៦២.........អយប

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**យើង សៀង សុខ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

បញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសវនាការ:

នាម-គោត្តនាម ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅ សង្កាត់លេខ៣ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះ ផ្លូវជាតិលេខ២ ភូមិព្រែក តាគង់២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្ដាយឈ្មោះ

ប្រពន្ធឈ្មោះ មានកូន ជាន់តិជន ។

អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ៖ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ដើមបណ្ដឹងឈ្មោះ បានឃើញនៅលើទំព័រហ្វេសបុករបស់ឈ្មោះ បានបង្ហោះអត្ថបទដែលមានខ្លឹមសារមួលបង្កាច់ខុសពីការពិត ដែលថាដើមបណ្ដឹងបានណែនាំដល់មន្ត្រីរបស់ខ្លួនអ្នកគាំទ្រ និងបណ្ដាញរួមបញ្ចូលទាំងមន្ត្រីរាជការស៊ីវិល ប៉ូលីស និងទាហាន ដើម្បីបង្កើតគណនីយក្លែងក្លាយ ក្នុងគោលបំណងផ្ដល់ការ

ជាបទល្មើស **បរិហារកេរ្តិ៍ជាសាធារណៈ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩-មីនា-២០១៦ តាមបញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

សវនាការនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ វេលាម៉ោង ៨និង០០នាទីព្រឹក នៅសាលសវនាការទី៤ សាលាដំបូងរាជធានីភ្នំពេញ ។

សាមីខ្លួនអាចពឹងមេធាវីឲ្យអមខ្លួនបាន ។

សាមីខ្លួនត្រូវបង្ហាញខ្លួនឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទង នឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០១៦

**តំណាងអយ្យការ**

សៀង_សុខ
ព្រះរាជអាជ្ញារង

អាសយដ្ឋាន : អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧,២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Address : #25-27, Street 217-213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia
ទូរសារ-ទូរស័ព្ទ: (៨៥៥ -២៣ ៨៨ ២០ ៥៩
Fax-Phone : (855)-23 88 20 59

ឧបសម្ព័ន្ធទី៦

ការិយាល័យមេធាវី…………….
លេខ:…………….

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបមន្តទី ២៩

**<u>ពាក្យបណ្តឹងសុំឱ្យធ្វើការចោទប្រកាន់</u>**

ខ្ញុំមេធាវី………………………………អត្តលេខ………….. សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ………………………………… ត្រូវជា………………………………… ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ……………. ចុះថ្ងៃទី……….. ខែ……….. ឆ្នាំ………..របស់សាលាដំបូង …………………………………………….។

**<u>សូមគោរពជូន</u>**

……………………………………………………………….

**<u>កម្មវត្ថុ:</u>**ប្តឹងសុំឲ្យលោកព្រះរាជអាជ្ញាមេត្តាពិនិត្យនិងសុំធ្វើការចោទប្រកាន់លើឈ្មោះ……………………. ភេទ………..អាយុ…….ឆ្នាំ ជនជាតិ……..សញ្ជាតិ……….. មុខរបរ……………………. អាសយដ្ឋានផ្ទះលេខ…….. ផ្លូវលេខ……….. ក្រុម…….. ភូមិ……………………… ឃុំ/សង្កាត់…………………… សង្កាត់/ខ័ណ្ឌ…………………………… ខេត្ត/រាជធានី ……………………………។

**<u>យោង:</u>** - មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- សំណុំរឿងព្រហ្មទណ្ឌលេខ……………………ចុះថ្ងៃទី………..ខែ…………..ឆ្នាំ…………..
- ពាក្យការពារក្តីចុះថ្ងៃទី………..ខែ…………………..ឆ្នាំ…………….
- ពាក្យបណ្តឹងរបស់កូនក្តីជាជនរងគ្រោះចុះថ្ងៃទី…………..ខែ………..ឆ្នាំ…………..។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំជាមេធាវីសូមជម្រាបជូនលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា៖រឿងក្តីខាងលើ កូនក្តីខ្ញុំ បានប្តឹងមកព្រះរាជអាជ្ញាអស់រយៈពេល.............. ប៉ុន្តែមកដល់ពេលនេះលោកព្រះរាជអាជ្ញាមិនទាន់មានចំណាត់ការទៅលើជនល្មើសនៅឡើយ ។

ករណីនេះខ្ញុំជាមេធាវីឲ្យជនរងគ្រោះស្នើសុំលោកព្រះរាជអាជ្ញាមេត្តាពិនិត្យផ្លូវច្បាប់និងសូមមានវិធានការណ៍ចោទប្រកាន់តាមនីតិវិធីដោយក្តីអនុគ្រោះ។

ធ្វើនៅ………………..ថ្ងៃទី……… ខែ……… ឆ្នាំ………..
**ហត្ថលេខា និងត្រា**

**<u>ភ្ជាប់មកជាមួយ</u>**
-ពាក្យបណ្តឹង
-ឯកសារពាក់ព័ន្ធក្នុងសំណុំរឿង

អាសយដ្ឋានផ្ទះលេខ…………ផ្លូវ………………ភូមិ…………………ឃុំ/សង្កាត់……………………ស្រុក/ខណ្ឌ…………………ខេត្ត/រាជធានី…………..
ទូរស័ព្ទ: ……………………….ទូរសារ:……………………….. អ៊ីម៉ែល: ………………………………………..

ឧបសម្ព័ន្ធទី៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤១០០
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩

# ដីកាកោះ

**យើង សេង គីមឡាក់ តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ : ជា ជនជាប់សង្ស័យ

អាសយដ្ឋាន : ផ្ទះលេខ ផ្លូវជាតិលេខ ក្រុមទី ភូមិ សង្កាត់ ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

អោយចូលទៅកាន់ : **អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ**

នៅថ្ងៃទី : **៣១** ខែ **កក្កដា** ឆ្នាំ **២០១៩** វេលាម៉ោង **៨:៣០** នាទី ព្រឹក

ដើម្បី : សាកសួរ

ពីដំណើររឿង : បណ្តឹងរបស់លោកមេធាវី ហាក់ សៀកលី . លោកមេធាវី ពេជ្រ សូរិយា និងលោកមេធាវី ចៅ ប៊ុនហួន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ។

សាមីខ្លួនត្រូវអញ្ជើញ តាមដីកាកោះនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទង នឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃចន្ទ ៧កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៩
**ជ.ព្រះរាជអាជ្ញា**

**សេង_គីមឡាក់**
**ព្រះរាជអាជ្ញារង**

យើង.................................................ជា.................................................
បានប្រគល់លិខិតអញ្ជើញនេះអោយឈ្មោះ.................................................
ទីលំនៅសព្វថ្ងៃភូមិ.....................................ឃុំ-សង្កាត់.....................................
ស្រុក-ខណ្ឌ.................................................ខេត្ត-ក្រុង.....................................
នៅថ្ងៃទី..........ខែ...................ឆ្នាំ.................... ផ្ទាល់រួចហើយ ដោយយើងបានទុក
ចុងដីកានេះមួយច្បាប់អោយសាមីខ្លួន ហើយប្រាប់ថាអោយសាមីខ្លួនប្រគល់ចុងដីកា
នេះដល់ក្រឡាបញ្ជី នៅពេលខ្លួនចូលទៅដល់សាលាដំបូង (តុលាការ) ឬ អយ្យការ ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**
**ហត្ថលេខា ឬផ្តិតមេដៃ**

ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**៣ ម ៨**

## ដីកាបង្គាប់ឲ្យឃុំខ្លួន

លេខ: ២៩៤ (ដ)/២០

យើង **មុយ សុត័ក្រ** ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តសៀមរាប។

បានឃើញ មាត្រា ២០៣ , ២០៤ , ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៧៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

បានឃើញ សំណុំរឿងស៊ើបសួរលេខ ២២១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣២៨ អ.យ/២០ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

បានឃើញសំណុំរឿងទាក់ទងនឹង៖

ឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រត់កង់បី ទីកន្លែងកំណើតនៅ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" ប្រពន្ធឈ្មោះ មានកូនចំនួន ទោសពីមុន "គ្មាន"។

ពីបទ ៖ **ខ្លែងព័ត៌មាន** ប្រព្រឹត្តនៅ(លើបណ្ដាញសង្គមហ្វេសប៊ុក) ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៥ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ **៤៣៩ (ដ)/២០** ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

### សម្រេច

១-បញ្ជាឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ហៅ ទៅពន្ធនាគារខេត្តសៀមរាប ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

២-បង្គាប់ឲ្យប្រធានពន្ធនាគារខេត្តសៀមរាប ទទួលជននេះ និងឃុំខ្លួនជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈទាំងអស់ នៅពេលត្រូវបានបង្ហាញដីកានេះ សហការអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅសៀមរាប, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

មុយ_សុត័ក្រ

ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

25/1

អយ្យការអមសាលាដំបូង
ខេត្តកំពង់ស្ពឺ
មកដល់ថ្ងៃទី 20.12.12
លេខ 1665

**សាលាដំបូងខេត្តកំពង់ស្ពឺ**
មន្ទីរស៊ើបសួរ (គ)
សំណុំរឿងលេខ ២៥០/២១.០៥.០៥
លេខស៊ើបសួរ ១៧៥/០៨.០៧.០៥
លេខ....៣៥៥......

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

-មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ

យើង **សុខ ប៊ុណ្ណារិទ្ធិ** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១២៧១ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹង:

| |
|---|
| ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិ ខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិត្បែស ឃុំល្វើស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ សព្វថ្ងៃនៅភូមិត្បែស ឃុំល្វើស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (ស្លាប់) ប្រពន្ធឈ្មោះ មានកូន នាក់ ប្រវត្តិទោស គ្មាន ។ |

-ជននេះត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យពីបទ ប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តនៅភូមិត្បែស ឃុំល្វើស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៥ តាមមាត្រា ៨ នៃច្បាប់ស្តីពីស្ការទម្ងន់ទោសនៃបទឧក្រិដ្ឋ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ។

-បានឃើញមាត្រា ១៩៥.១៩៦.១៩៧ .១៩៨ និង២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សម្រេចចេញដីកានេះ និងបង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកំលាំងសាធារណៈទាំងអស់ ចាប់ខ្លួនឈ្មោះខាងលើនេះមកចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

កំពង់ស្ពឺ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០១២
**ចៅក្រមស៊ើបសួរ**

សុខ-ប៊ុណ្ណារិទ្ធិ

ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម

សាលាដំបូងខេត្ត

.................................

លេខ:.......................

## ដីកាតម្កល់រឿងទុកឥតចាត់ការ "១"

យើង.................................ព្រះរាជអាជ្ញាអមតុលាការរាជធានី/ខេត្ត........................។

- បានឃើញពាក្យបណ្តឹង ឬសំណុំរឿងព្រហ្មទណ្ឌលេខ...............................................

ចុះថ្ងៃទី.................ខែ...............ឆ្នាំ...............ដែលមានដំណើររឿងដូចតទៅ................

.......................................................................................................................

.......................................................................................................................

- បានឃើញ...........................................................................................................

.......................................................................................................................

ក្រោយពីពិនិត្យសំណុំរឿង...........................................................................................

យល់ឃើញថា "២"...................................................................................................

.......................................................................................................................

ហេតុដូច្នេះ សម្រេចតម្កល់រឿងទុកឥតចាត់ការតទៅ ។

ធ្វើនៅ.........ថ្ងៃទី..........ខែ.........ឆ្នាំ.........

**ព្រះរាជអាជ្ញា**

---

**កំណត់សម្គាល់**

"១" ដីកាសម្រេចនេះគ្មានអាជ្ញាជាសេចក្តីសម្រេចដាច់ខាតនៅឡើយទេ អាចប្រែប្រួលបានកុំឲ្យដកបណ្តឹងអាជ្ញាត្រូវរលត់ដោយផុតអាជ្ញាយុកាល ។

"២" រឿងមិនចូលជាបទល្មើសព្រហ្មទណ្ឌ រដ្ឋប្បវេណី ‧ ពាណិជ្ជកម្ម រដ្ឋបាល ‧ ការងារ ។ ល ។

ឧបសម្ព័ន្ធទី១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖ ៣៨៨ "ឈ" ព្រ.ទ

**<u>ដីកាបង្គាប់ឱ្យចូលខ្លួន</u>**

(មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង **លាង សំណាត់** ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១១២៥ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣០៤១ អ.យ.ប ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ។

បើកការស៊ើបសួរលើឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ១៩៨០ ជាតិខ្មែរ ពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ , ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣០៥ មាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

បង្គាប់មកឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ១៩៨០ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (អាស័យដ្ឋានចុងក្រោយ) ។

ឱ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់"ឈ" ជាន់ទី៤ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ។**

ដើម្បី៖ មកសាកសួរយកចម្លើយ

ពីដំណើររឿង៖ បរិហារកេរ្តិ៍ជាសាធារណៈ , ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍

សាមីខ្លួនត្រូវយកលិខិតផ្សេងៗដែលទាក់ទងនិងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន ។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើនេះទេ <u>យើងនិងចេញដីកាបង្គាប់ឱ្យនាំខ្លួន</u> ។

ថ្ងៃអង្គារ ០២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ , ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

លាង សំណាត់

អាសយដ្ឋាន: អគារលេខ ២៥, ២៦ និង ២៧ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Adress: #25, 26 and 27, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ៥០ ៨០
Fax-Phone : (855) - 23 88 50 80

ឧបសម្ព័ន្ធទី១២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**
លេខ......១៩៦.........សត.ប្រក.០១៨

## សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

បានឃើញ មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០-០៨-២០០៧ ស្តីពី «ការតម្កល់រឿងទុកឥតចាត់ការ»។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៧១៨ ចុះថ្ងៃទី ០១-០២-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿង «តម្កល់រឿងទុកឥតចាត់ការ» ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍លេខ ១៨៨ ចុះថ្ងៃទី ១៣-០៦-២០១៨ ។

បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ០១-០២-២០១៨ របស់ឈ្មោះ សុខ សុវណ្ណវឌ្ឍនាសារពង្ស ភេទ ប្រុសអាយុ ៨៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្តឹងចោទប្រកាន់លើឈ្មោះ ភេទ ស្រីអាយុ ២៣ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ២៧០ ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ និងបទញុះញង់ឱ្យមានការរើសអើង ។

បានឃើញ ពាក្យបណ្តឹងតប ចុះថ្ងៃទី ០៩-០២-២០១៨ របស់ឈ្មោះ . ភេទ ប្រុស អាយុ ៨៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ សង្កាត់វាលវង់ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្តឹងចោទប្រកាន់លើឈ្មោះ ភេទ ស្រី អាយុ ២៣ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ផ្លូវ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ បទញុះញង់ឱ្យមានការរើសអើង និងបទប្តឹងបរិហារបង្ខាច់កេរ្តិ៍ តាមបញ្ញត្តិមាត្រា៣០៥ មាត្រា៤៩៦ និងមាត្រា៣១១ ។

បានឃើញ ដីកាសម្រេចបំបែកសំណុំរឿងលេខ ០៩១ អ.យ.ដ ចុះថ្ងៃទី ២៨-០៣-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងលេខ ០២៥ អ.យ.ដ ចុះថ្ងៃទី ០៥-០៨-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ១០២៣ អ.យ.ដ ចុះថ្ងៃទី ២៣-០៥-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សេចក្តីចម្លងបណ្តឹងតវ៉ាលេខ ៥៧ ចុះថ្ងៃទី ០៧-០៦-២០១៨ របស់ឈ្មោះ សុខ សុវណ្ណវឌ្ឍនាសារពង្ស ប្តឹងតវ៉ានឹងដីកាតម្កល់រឿងទុកឥតចាត់ការខាងលើ ។ល។

បានឃើញ កំណត់ហេតុសួរយកចម្លើយដើមបណ្តឹងឈ្មោះ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ថា៖ ខ្លួនសូមរក្សាពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី ០១-០២-២០១៨ ប្តឹងឈ្មោះ ម្ចាស់គណនីផេកហ្វេសប៊ុក (Facebook Page) ឈ្មោះ ភេទ ស្រីអាយុ ២៣ឆ្នាំ ពីបទ៖ បរិហារកេរ្តិ៍ញុះញង់ឱ្យមានការរើសអើង ទុកនៅដដែល កុំកែប្រែទេ ។ សូមបញ្ជាក់ថា នៅថ្ងៃទី ៣០-០១-២០១៨ វេលាម៉ោង ២និង១៧នាទីរសៀល ឈ្មោះ

គាត់ប្រើប្រាស់គេហទំព័របណ្តាញសង្គមរបស់គាត់ឈ្មោះ ដោយគាត់បានយកឈ្មោះគណនីហ្វេសប៊ុក របស់ខ្លួនឈ្មោះ , សរសេរថា "សារព្រមានឈ្មោះ បញ្ឈប់ជាបន្ទាន់ការនិយាយ ប្រើរូប និងឈ្មោះ បរិហារកេរ្តិ៍ ។ គាត់ពុំបានធ្វើនយោបាយលាក់ឈ្មោះ លាក់ប្រវត្តិរងពាក្យបណ្តឹងបោកប្រាស់លុយគេជាច្រើននាក់ និងតែងតែ "វើផ្ទះ" ស្មើរពល់នៃ ដូចខ្លួននោះទេ ។ គាត់ក៏ពុំបានធ្វើនយោបាយក្បត់ជាតិ លាបពណ៌ ហិង្សា ជាប់គុក រត់ចោលស្រុក សុំអន្តរជាតិបិទទីផ្សារ កាត់ជំនួយដូចឈ្មោះ ដែរ" ។ គាត់ធ្វើនយោបាយដោយត្រង់ៗ តាមឆន្ទៈគាត់ តាមបែបបច្ចេកទេសស្របច្បាប់ ដោយសន្តិភាព ដើម្បីជាតិ និងប្រជាជន ។ គាត់ឈ្មោះ នេះជាសារព្រមានលើកទី១ និងជាលើកចុងក្រោយ នៅថ្ងៃទី ០៦-០២-២០១៨ វេលាម៉ោង ១និង១៣នាទីរសៀល ថា៖ "សារជូនឈ្មោះ គាត់បានផ្តល់ឱកាសជូនគាត់ដោយព្រមានខ្លួនឱ្យបញ្ឈប់យករូប និងឈ្មោះគាត់ វាយប្រហារបរិហារគាត់ តែខ្លួននៅតែមើលងាយបំពានគាត់ និងប្តឹងគាត់ទៀត ដោយខ្លួនបានជេរគាត់វាយប្រហារគាត់ ៨ឆ្នាំហើយ ដោយបានថា៖ គាត់ជាស្រីបិសាច គាត់សមតែត្រវក្បាលស្បែកជើង ចង់ផ្តាច់ផ្លូវនយោបាយគាត់ និងប្រើរូបភាពបាញ់កាំភ្លើងគំរាមកំហែងអាយុជីវិតគាត់ និងមានច្រើនទៀត ។ គាត់បានផ្តល់ឱកាសជូនខ្លួន គឺគាត់មានចិត្តអាណិតខ្លួន តែខ្លួនមើលងាយទឹកចិត្តរបស់គាត់ ដោយខ្លួនបានប្រើប្រាស់ឈ្មោះក្លែងក្លាយ សូម្បីតែពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី ០១-០២-២០១៨ ក៏ខ្លួនប្រើអាសយដ្ឋានក្លែងក្លាយ (គ្មានលេខផ្លូវ) ។ ពេលនេះហួសពេលហើយព្រោះតែចរិកឈ្លើយ ការរួតក្អេងក្អាងរបស់ខ្លួន គាត់បានស្នើសុំឱ្យតុលាការបន្តនីតិវិធីចាត់ការខ្លួនតាមច្បាប់ បើខ្លួនជាប់គុកសូមខ្លួនកុំស្តីបន្ទោសគាត់" ដូចនេះការបង្ហោះរបស់ឈ្មោះ

លើបណ្តាញសង្គមរបស់គាត់ ធ្វើឱ្យប៉ះពាល់ដល់ មុខជំនាញរបស់ខ្លួន ធ្វើឱ្យអតិថិជនរបស់ខ្លួនបាត់បង់ទំនុកចិត្តលើខ្លួន ជាពិសេសបាត់បង់កិត្តិយសរបស់ខ្លួន ដោយបានថាខ្លួនបោកប្រាស់គេ ធ្វើឱ្យមុខជំនួញរបស់ខ្លួនធ្លាក់ចុះជាខ្លាំង (ខ្លួនរកស៊ីសាងសង់ធ្វើផ្ទះល្វែងលក់) និងការសរសេររបស់គាត់បានធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពឯកជនរបស់ខ្លួន ដោយបានធ្វើការរំលោភលើសិទ្ធិសេរីភាពក្នុងជ្រើសរើសលំនៅដ្ឋាន ។ កន្លងមកខ្លួន និងឈ្មោះ ពុំដែលមានទំនាស់នឹងគ្នាទេ គឺខ្លួនគ្រាន់តែធ្វើការរិះគន់គាត់ក្នុងន័យស្ថាបនាដោយយោងថាគាត់ជាសាធារណៈបុគ្គល ចំណែកខ្លួនគ្រាន់តែជារូបវន្តបុគ្គលតែប៉ុណ្ណោះ ។

បានឃើញ កំណត់ហេតុសួរយកចម្លើយជនសង្ស័យឈ្មោះ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ថា៖ ចំពោះពាក្យបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី ០១-០២-២០១៨ ប្តឹងខ្លួនពីបទ៖ បរិហារកេរ្តិ៍ជាសាធារណៈ ឬក៏ញុះញង់ឱ្យមានការរើសអើងទៅលើឈ្មោះ ឡើយ ។ ការសរសេររបស់ខ្លួនឈ្មោះ

គាត់រងពាក្យបណ្តឹងបោកប្រាស់ប្រាក់គេជាច្រើននាក់ ចំណុចដែលខ្លួនសរសេរនេះគឺខ្លួនគ្មានចេតនាចោទប្រកាន់គាត់ទេ ដោយសារខ្លួនពិតជាបានឃើញពាក្យបណ្តឹងដែលគាត់ប្តឹងពីបទ ឆបោកប្រាក់ ពិតប្រាកដមែន ហើយរាល់ពាក្យបណ្តឹងដែលជនរងគ្រោះប្តឹងគាត់នេះ ខ្លួនឃើញជនរងគ្រោះបានបង្ហោះតាមបណ្តាញសង្គម Facebook និងជនរងគ្រោះ ផ្ញើក្នុង Comment លើបណ្តាញសង្គម Facebook របស់ខ្លួន ។ ចំពោះការសរសេរថា "ខ្លួនក៏ពុំធ្វើនយោបាយក្បត់ជាតិលាបពណ៌ ហិង្សា ជាប់គុក រត់ចោលស្រុក សុំអន្តរជាតិបិទផ្សារ កាត់ជំនួយ ដូច ... ដែរ ។ " ការសរសេរនេះខ្លួនបានប្រៀបធៀបខ្លួនទៅឈ្មោះ ហើយពុំបានប្រៀបធៀបឈ្មោះ ទៅនរណាម្នាក់ឡើយ ។ ម្យ៉ាងវិញទៀតការសរសេរគ្មានអ្វីប៉ះពាល់ដល់ឈ្មោះ ឡើយ គឺគ្រាន់តែសាររបស់ខ្លួនធ្វើការព្រមាននិងចង់ឱ្យគាត់ទទួលស្គាល់កំហុស ដែលគាត់បានប្រព្រឹត្តខុសលើរូបខ្លួនទើបខ្លួនធ្វើការប្តឹងគាត់មកតុលាការនៅថ្ងៃទី ០៨-១២-២០១៧ តែប៉ុណ្ណោះ ។ ចំពោះការសរសេរថា "រើផ្ទះ ស្មើរាល់ខែ" ខ្លួនមានបំណងថា ពេលតុលាការកោះហៅគាត់ចំនួន ៣ដង លើបណ្តាញសង្គមរបស់ខ្លួន គឺកោះលើទី១ លើកទី២ លើកទី៣ គាត់បានរើផ្ទះទាំងបីដង ហើយពុំព្រមទទួលដីកាដោះហៅពីតុលាការទេ ខ្លួនយោងតាមដីកាកោះរបស់តុលាការទាំងបីលើក ។ ការសរសេរថា "ខ្លួនជាស្រីបិសាច .... ខ្លួនសមតែត្រូវក្បាលស្បែកជើង ចង់ផ្តាច់ផ្លូវនយោបាយខ្លួន និងប្រើរូបភាពបាញ់កាំភ្លើងគំរាមកំហែងអាយុជីវិតខ្លួន ... និងមានច្រើនទៀត" គឺឈ្មោះ ពិតជាបានសរសេរបង្ហោះជេរខ្លួនពិតមែន ដូចមានក្នុងពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី ០៨-១២-២០១៧ ដែលបានប្តឹងឈ្មោះ

ពីបទ៖ បរិហារកេរ្តិ៍ ជេរប្រមាថជាសាធារណៈ និងបទគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ និងបទ ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទញុះញង់ឱ្យមានការរើសអើង ព្រមទាំងបទកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ។ ចំពោះការសរសេរថា "ខ្លួនផ្តល់ឱកាសជូនលោកដោយព្រមានលោកឱ្យបញ្ឈប់យករូប និងឈ្មោះខ្លួនវាយប្រហារបរិហារខ្លួន តែគាត់នៅតែមើលងាយបំពានខ្លួន និងប្តឹងខ្លួនទៀត ដោយគាត់បានជេរខ្លួន ៨ឆ្នាំ ហើយ" ខ្លួនបានសរសេរនេះចង់ឱ្យឈ្មោះ បញ្ឈប់ការជេរប្រមាថមកលើរូបខ្លួនបន្តទៅទៀតតែប៉ុណ្ណោះ គ្មានអ្វីប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ឈ្មោះ

និងគ្មានការញុះញង់ឡើយ ដោយសារតែឈ្មោះ ពិតជាប្រព្រឹត្តអ្វីដូចដែលខ្លួនបាននិយាយពិតប្រាកដមែន ។ ឈ្មោះ បានដាក់ពាក្យ

បណ្តឹងតប ចុះថ្ងៃទី ០៨-០២-២០១៨ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧៧០៩ ចុះថ្ងៃទី ០៨-១២-២០១៧ ដែលមានខ្លឹមសារដូចគ្នានឹងបណ្តឹងរបស់គាត់ក្នុងសំណុំរឿងនេះដែរ ។

បានឃើញ ឯកសារផ្សេងៗពាក់ព័ន្ធក្នុងសំណុំរឿងខាងលើ ។

យល់ឃើញថា ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ១០២៣ ព.យ.ជ ចុះថ្ងៃទី ២៣-០៥-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុ សំអាងច្បាប់ និងសេចក្តីសម្រេច មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះសម្រេច

តម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ១០២៣ ព.យ.ជ ចុះថ្ងៃទី ២៣-០៥-២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

ថ្ងៃ.ពុធ.៨កើត......ខែ.អស្សុជ.... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី..១៧..ខែ.តុលា... ឆ្នាំ ២០១៨

អគ្គព្រះរាជអាជ្ញា

អ៊ុក_សាវុធ

ឧបសម្ព័ន្ធទី១៣

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង **********

.........................

***********

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

លេខ..................... ************

យើង.......................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ....................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ..................... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ ............. និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភស្តុតាងនានា ។

សម្រេចផ្ដើមចោទប្រកាន់ឈ្មោះ ......................................... ភេទ............ អាយុ .........ឆ្នាំ ជាតិ........... របរកសិ........................................ ទីលំនៅបច្ចុប្បន្ននៅភូមិ.........................ឃុំ-សង្កាត់................................. ស្រុក-ខណ្ឌ..........................................ខេត្ត-ក្រុង.................................ទោសពីមុន ........................ និងគូកន ។ ឪពុកឈ្មោះ............................................ "រ-ស" ម្ដាយឈ្មោះ ......................................... "រ-ស" ប្ដីឬប្រពន្ធឈ្មោះ...............................................រ-ស"មានកូន ឬនៅលីវ ................................ ត្រូវជាប់ចោទពីបទ.............................................................................. ប្រព្រឹត្តនៅភូមិ............................................ ឃុំ-សង្កាត់........................... ស្រុក-ខណ្ឌ............................... ខេត្ត-ក្រុង.........................................កាលពីថ្ងៃទី ......... ខែ ................. ឆ្នាំ .................. តាមមាត្រា................................................................ នៃច្បាប់ ..........................................................................................................................................។
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................។
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................។
..........................................................................................................................................
..........................................................................................................................................

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន. គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... ............................................................... ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ .......................................... ។

ធ្វើនៅ........................... ថ្ងៃទី........... ខែ................. ឆ្នាំ.............

**ព្រះរាជអាជ្ញា**